ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# មគ្គុទ្ទេសក៍ជាតិ
# ព្យាបាលជម្ងឺគ្រុនចាញ់

ឧសភា ២០១២

World Health Organization



## អារម្ភកថា

ជម្ងឺគ្រុនចាញ់ បានបង្កគ្រោះថ្នាក់ដល់មនុស្សជាតិចាប់តាំងពីសម័យបុរាណមកហើយវានៅតែជាជម្ងឺឆ្លងមួយដែលសំខាន់និងបង្កមហន្តរាយធ្ងន់ធ្ងរបំផុតមួយក្នុងពិភពលោក។ ពាក់កណ្តាលនៃប្រជាជនក្នុងពិភពលោកដែលមានចំនួន៣,៣ពាន់លាននាក់រស់នៅក្នុង ប្រទេស ចំនួន ១០៦ កំពុងប្រឈមមុខនឹងការឆ្លងជម្ងឺនេះ។ នៅក្នុងប្រទេសកម្ពុជាទោះបីជាមានតំបន់មួយចំនួនតូចប៉ុណ្ណោះដែលមានកើតនូវជម្ងឺគ្រុនចាញ់ (តំបន់ព្រៃភ្នំ) ក៏មានប្រជាជនប្រមាណ២,៨៩លាននាក់ដែលរស់នៅក្នុងចម្ងាយ២គមពីព្រៃកំពុងប្រឈមមុខនឹងជម្ងឺគ្រុនចាញ់នេះដែរ។ ជម្ងឺគ្រុនចាញ់ចំនួន 62,770 ករណីត្រូវបានព្យាបាលដោយសេវាសុខភាពសាធារណៈ និងជម្ងឺគ្រុនចាញ់ចំនួន 46,215 ករណីត្រូវបានព្យាបាលដោយអ្នកស្ម័គ្រចិត្តភូមិនៅក្នុងកំឡុងឆ្នាំ ២០១១ ។

ជម្ងឺគ្រុនចាញ់នៅក្នុងប្រទេសកម្ពុជា គឺជាកត្តាដ៏សំខាន់មួយដែលបង្កដល់ភាពស្លេកស្លាំង ផលវិបាកក្នុងពេលមានផ្ទៃពោះ ទារកកើតមិនគ្រប់ទម្ងន់និងការលូតលាស់មិនល្អរបស់កុមារ ។ សំខាន់ជាងនេះទៅទៀតការព្យាបាលជម្ងឺគ្រុនចាញ់បច្ចុប្បន្ន និងកិច្ចខិតខំប្រឹងប្រែងកំចាត់ជម្ងឺនេះនៅក្នុងប្រទេសកម្ពុជាអាចត្រូវរារាំងដោយការកើតឡើងនិងការរីករាលដាលនូវភាពស៊ាំនឹងថ្នាំអាតេមីស៊ីនីន ដែលត្រូវបានរកឃើញនាពេលថ្មីៗនេះនៅក្នុងភាគខាងលិចនៃប្រទេសនៅតាមបណ្តោយព្រំដែនថៃ-កម្ពុជា។ការព្យាបាល ដោយថ្នាំអាតេមីស៊ីនីនតែមួយមុខ និងការប្រើឱសថ ប្រឆាំងនឹងជម្ងឺគ្រុនចាញ់ មិនគ្រប់តាមកម្រិតគុណភាពនិងក្លែងក្លាយនៅក្នុងវិស័យឯកជន

គឺជាបញ្ហាប្រឈមខ្លះក្នុងចំណោមបញ្ហាប្រឈមនានា ក្នុងការគ្រប់គ្រងករណី ជម្ងឺគ្រុនចាញ់នៅក្នុងប្រទេសកម្ពុជា។

ដើម្បីសម្រេចជោគជ័យ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជម្ងឺគ្រុនចាញ់ក្នុងឆ្នាំ ២០២៥ ដែលគាំទ្រ នឹងអនុម័ត ដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសុខាភិបាលកំពុងរៀបចំបោះពុម្ពអត្ថបទដែលបានកែសម្រួលនៃមគ្គុទ្ទេសក៍ជាតិសម្រាប់ព្យាបាលជម្ងឺគ្រុនចាញ់ដោយដាក់បញ្ចូលព័ត៌មាន បច្ចុប្បន្នភាពអំពីរូបមន្តថ្មី ACT ដែលបានផ្តល់អនុសាសន៍នៅឯកិច្ចប្រជុំស្តីពីគោលនយោបាយឱសថជម្ងឺគ្រុនចាញ់ថ្មីធ្វើឡើងនៅក្នុងខែមេសា ឆ្នាំ ២០១០ យោងទៅតាមតម្រូវការក្នុងស្រុក និងការតាមដានមើលប្រសិទ្ធភាពរបស់ឱសថប្រឆាំងនឹងជម្ងឺគ្រុនចាញ់។ការព្យាបាលរួមបញ្ចូលគ្នា ដោយយកអាតេមីស៊ីនីនជាគោល(ឱសថប្រឆាំងនឹងគ្រុនចាញ់២ប្រភេទប្រើនៅ ក្នុងការ រួមបញ្ចូលក្នុងដូសតែមួយ) ត្រូវបានណែនាំយោងតាមការឯកភាពគ្នាក្នុងចំណោមអ្នកជំនាញការជាតិនិងអន្តរជាតិនៅឯកិច្ចប្រជុំនោះ។

មគ្គុទ្ទេសក៍នេះត្រូវបានតាក់តែងឡើងសម្រាប់គ្រូពេទ្យ និងបុគ្គលិកនៅតាមកម្រិតថ្នាក់នីមួយៗនៃមូលដ្ឋានសុខាភិបាល (មន្ទីរពេទ្យ បង្អែក មណ្ឌល សុខភាព និងប៉ុស្តិ៍សុខភាព) វិស័យឯកជន ក៏ដូចជា នៅ ថ្នាក់សហគមន៍ (តាមរយៈអ្នកស្ម័គ្រចិត្តភូមិព្យាបាលជម្ងឺគ្រុនចាញ់) សម្រាប់កែលំអការគ្រប់គ្រងករណីជម្ងឺគ្រុនចាញ់ និងដើម្បីកាត់បន្ថយអត្រាមរណភាពរបស់វា។

គោលបំណងចម្បងនៃការបោះពុម្ពឯកសារនេះ គឺដើម្បីផ្តល់អ្នកទាំងអស់ដែលពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងជម្ងឺគ្រុនចាញ់ នៅក្នុងវិស័យផ្សេងៗ និង កម្រិតថ្នាក់នានានូវគោលការណ៍ណែនាំច្បាស់លាស់ និង ជាក់ស្តែង

សម្រាប់ធ្វើរោគវិនិច្ឆ័យឲ្យបានរហ័សពីដំបូង និងការព្យាបាលជម្ងឺគ្រុនចាញ់ភ្លាមៗនិងសមស្រប។ព័ត៌មានដែលបង្ហាញនៅទីនេះ គឺពាក់ព័ន្ធទៅនឹងការព្យាបាល៖

- ជម្ងឺគ្រុនចាញ់ដែលគ្មានផលវិបាក
- ជម្ងឺគ្រុនចាញ់ដែលធ្ងន់ធ្ងរ ឬមានផលវិបាក

មគ្គុទ្ទេសក៍នេះ មិនផ្តោតលើការប្រើឱសថសំរាប់បង្ការជម្ងឺគ្រុនចាញ់ ឬការព្យាបាលបង្ការម្តងម្កាលឡើយ លើកលែងតែសម្រាប់អ្នកធ្វើដំណើរបណ្តោះអាសន្នទៅកាន់តំបន់ដែលចំលងជម្ងឺគ្រុនចាញ់។

ក្រសួងសុខាភិបាលសង្ឃឹមយ៉ាងមុតមាំថា មគ្គុទ្ទេសក៍នេះនឹងជួយសម្រួលដល់ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជម្ងឺគ្រុនចាញ់ប្រកបដោយប្រសិទ្ធភាពសមស្រប និងទាន់ពេលវេលា ព្រមទាំងរួមចំណែកយ៉ាងច្រើនដល់ការកាត់បន្ថយបន្ទុកជម្ងឺនេះនៅក្នុងប្រទេស។ ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណដល់អង្គការសុខភាពពិភពលោក ដែលបានសហការនៅក្នុងការធ្វើបច្ចុប្បន្នកម្មឯកសារថ្មីនេះ។

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

វេជ្ជ. ម៉ម ប៊ុនហេង

# គោលដៅរួមនិងគោលដៅជាក់លាក់នៃកម្មវិធីជាតិកំចាត់ជម្ងឺគ្រុនចាញ់

## គោលដៅរួម៖

ដើម្បីធ្វើដំណើរឆ្ពោះទៅរកដំណាក់កាលត្រៀមលុបបំបាត់គ្រុនចាញ់នៅទូទាំងប្រទេសកម្ពុជា ដោយ ធ្វើកា រខិត ខំពិសេស ដើម្បី ទប់ស្កាត់ ភាព ស៊ាំមេរោគជម្ងឺគ្រុនចាញ់ ប្រភេទផ្លាស្មូដ្យូមហ្វាល់ ស៊ីប៉ារ៉ូម ទៅ នឹង ថ្នាំអាតេមីស៊ីនីន។

### គោលដៅ៖

1. ដើម្បីលើកកម្ពស់ភាពទទួលបាននូវសេវារោគវិនិច្ឆ័យនិងព្យាបាលជម្ងឺ គ្រុនចាញ់រហ័សពីដំបូង។
2. ដើម្បីកាត់បន្ថយសម្ពាធនៃការប្រើប្រាស់ឱសថអាតេមីស៊ីនីន ដែលមាន ភាពស៊ាំនឹងមេរោគគ្រុនចាញ់។
3. ដើម្បីលើកកម្ពស់ភាពទទួលបាននូវវិធានការបង្ការ និងជាពិសេសបង្ការការ ចម្លងមេរោគគ្រុនចាញ់ដែលស៊ាំនឹងអាតេមីស៊ីនីន។
4. ដើម្បីបង្កើនការយល់ដឹងរបស់សហគមន៍និងការផ្លាស់ប្តូរឥរិយាបថក្នុងចំណោមប្រជាជនដែលប្រឈមមុខនឹងជម្ងឺគ្រុនចាញ់។
5. ដើម្បីផ្តល់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព (រួមទាំងប្រព័ន្ធព័ត៌មាន និងការអង្កេតតាមដាន) និងការសម្របសម្រួល។

### គោលបំណងទូលំទូលាយនៃការគ្រប់គ្រងករណីជម្ងឺគ្រុនចាញ់

- ដើម្បីព្យាបាលជម្ងឺ និងកាត់បន្ថយការឈឺ និងស្លាប់ដោយជម្ងឺគ្រុនចាញ់។
- ដើម្បីកាត់បន្ថយភ្នាក់ងារចម្លង

## គោលដៅជាក់លាក់នៃការគ្រប់គ្រងករណីជម្ងឺគ្រុនចាញ់

- ស្រាវជ្រាវរកឲ្យឃើញពីដំបូង និងការព្យាបាលប្រកបដោយប្រសិទ្ធភាពភ្លាមៗដើម្បីព្យាបាលជម្ងឺ និងបង្ការការវិវឌ្ឍន៍ទៅជាជម្ងឺធ្ងន់ធ្ងរ
- គ្រប់គ្រងឲ្យបានត្រឹមត្រូវនូវជម្ងឺធ្ងន់ធ្ងរដើម្បីទប់ស្កាត់មរណភាព។
- បង្ការភាពស៊ាំរបស់មេរោគទៅនឹងឱសថ
- កាត់បន្ថយការចម្លងជម្ងឺគ្រុនចាញ់

## សមាសភាគនៃការគ្រប់គ្រងករណីជម្ងឺគ្រុនចាញ់

- ការធ្វើរោគវិនិច្ឆ័យប៉ារ៉ាស៊ីតសាស្ត្រភ្លាមៗ
- ការព្យាបាលដោយប្រើឱសថដោយប្រសិទ្ធភាព
- ការបញ្ជូន (និងការព្យាបាលមុនពេលបញ្ជូន តាមការណែនាំ)
- ការផ្តល់ប្រឹក្សានិងការតាមដានមើលអ្នកជម្ងឺ
- បញ្ហានានាដែលទាក់ទងទៅនឹងរោគវិនិច្ឆ័យ៖ គោលនយោបាយ និងការធានាគុណភាព
- ឱសថ៖ ការផ្គត់ផ្គង់ និងការគ្រប់គ្រងសុវត្ថិភាព (ការអង្កេតឃ្លាំមើលឱសថ)
- គុណភាព (បញ្ហាគ្រប់គ្រង) និងភាពស័ក្តិសិទ្ធនៃការព្យាបាល

## តារាងមាតិកា


| លេខ | មាតិកា | ទំព័រ |
|---|---|---|
| 1. | របាយភាពស័ក្តិសិទ្ធិនៃឱសថប្រឆាំងនឹងជំងឺគ្រុនចាញ់ ជម្រើសទី១នៅក្នុងប្រទេសកម្ពុជា | 7 |
| 2. | ឯកសារយោងគន្លឹះសម្រាប់រោគវិនិច្ឆ័យនិងការព្យាបាល ជម្ងឺគ្រុនចាញ់ | 8-11 |
| 3. | របៀបធ្វើរោគវិនិច្ឆ័យជម្ងឺគ្រុនចាញ់ | 12-18 |
| 4. | ការព្យាបាលជម្ងឺគ្រុនចាញ់ស្រាលចំពោះមនុស្សពេញវ័យ | 19-29 |
| 5. | ការព្យាបាលជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរ ឬផលវិបាក ចំពោះមនុស្សពេញវ័យ | 30-48 |
| 6. | វិធីព្យាបាលជម្ងឺគ្រុនចាញ់ចំពោះកុមារ | 49-57 |
| 7. | ការគ្រប់គ្រងជម្ងឺគ្រុនចាញ់ចំពោះស្ត្រីមានផ្ទៃពោះ | 58-60 |
| 8. | ការព្យាបាលដោយប្រើព្រីម៉ាគីន PRIMAQUINE | 61-63 |
| 9. | ឧបសម្ព័ន្ធ | 64-73 |
| 10. | អនុសាសន៍ | |

# 1.របាយភាពស័ក្តិសិទ្ធិនៃឱសថប្រឆាំងនឹងជំងឺគ្រុនចាញ់ជម្រើសទី១នៅក្នុងប្រទេសកម្ពុជា



## 2. ឯកសារយោងគន្លឹះសម្រាប់រោគវិនិច្ឆ័យនិងការព្យាបាលជម្ងឺគ្រុនចាញ់

### តារាងស្តីពីការសម្រេចចិត្តព្យាបាលជំងឺគ្រុនចាញ់ក្នុងវិស័យសាធារណៈ



# តារាងស្តីពីការសម្រេចចិត្តព្យាបាលជំងឺគ្រុនចាញ់សម្រាប់អ្នកស្ម័គ្រចិត្តភូមិព្យាបាលជំងឺគ្រុនចាញ់ និង វិស័យឯកជន



## បញ្ជីឱសថសារវន្តសម្រាប់ព្យាបាលជម្ងឺគ្រុនចាញ់

**តារាងទី១៖ បញ្ជីឱសថប្រឆាំងនឹងជម្ងឺគ្រុនចាញ់ប្រើសម្រាប់ព្យាបាល**

| ឱសថ | មូលដ្ឋានសុខាភិបាលដែលប្រើឱសថគ្រុនចាញ់ | | | |
|---|---|---|---|---|
| | ថ្នាក់កណ្តាល /ខេត្ត | ស្រុក | VMW | ឯកជន |
| ឌីអ៊ីដ្រូអាតេមីស៊ីនីន ពីពេរ៉ាគីន (គ្រាប់) Dihydroartemisinin-Piperaquine (tab) | មាន | មាន | មាន | មាន |
| អាតេស៊ូណាត (Artesunate supp) | មាន | មាន | មាន | មាន |
| អាតេស៊ូណាត (Artesunate IV) | មាន | មាន | គ្មាន | គ្មាន |
| អាតេមេទែរ (Artemether IM) | មាន | មាន | គ្មាន | គ្មាន |
| តេត្រាស៊ីគ្លីន(Tetracycline ) | មាន | មាន | គ្មាន | គ្មាន |
| ដុកស៊ីស៊ីគ្លីន (Doxycycline) | មាន | មាន | គ្មាន | គ្មាន |
| គីនីន(Quinine Tablet) | មាន | មាន | គ្មាន | គ្មាន |
| គីនីន (Quinine IV) | មាន | មាន | គ្មាន | គ្មាន |
| អាតេស៊ុយណាត+មេហ្វ្លូគីន (A+M) | មាន | មាន | មាន | មាន |
| Atovaquone + Proquanil | * | * | * | គ្មាន |
| ព្រីម៉ាគីន(Primaquine) | * | * | * | គ្មាន |

IV = intravenous (តាមសរសៃ), IM = intramuscular (តាមសាច់ដុំ), supp = suppository (ស៊ុល)

VMW = Village Malaria Worker (អ្នកស្ម័គ្រចិត្តព្យាបាលជម្ងឺគ្រុនចាញ់ភូមិ)

*ការបញ្ចូលឱសថទាំងអស់នេះ នឹងធ្វើការណែនាំបណ្តើរៗសំរាប់មូលដ្ឋានសុខាភិបាល ដែលបានជ្រើសរើសដោយអាស្រ័យទៅលើការអនុម័តរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ក្រោយពីមានការពិនិត្យវាយតំលៃនូវសមត្ថភាព.

**តារាងទី២៖ ការទទួលខុសត្រូវរបស់ប្រព័ន្ធថែទាំសុខភាពនៅក្នុងការគ្រប់គ្រងករណីជម្ងឺគ្រុនចាញ់**

| សណ្ឋានគ្លីនិក | សេវាសុខភាពដែលផ្តល់ការព្យាបាល | | | | |
|---|---|---|---|---|---|
| | ថ្នាក់ កណ្តាល/ខេត្ត | អតីត មន្ទីរពេទ្យស្រុក | មណ្ឌល សុខភាព | VMW | ឯកជន** |
| ជម្ងឺគ្រុនចាញ់ស្រាល | មាន | មាន | មាន | មាន | មាន |
| ជម្ងឺគ្រុនចាញ់ក្នុងពេលមានផ្ទៃពោះ | មាន | មាន | មាន | មាន | បញ្ជូនទៅផ្នែកសាធារណ: |
| ជម្ងឺគ្រុនចាញ់នៅក្នុងកុមារក្រោម៥ឆ្នាំ | មាន | មាន | មាន | មាន | បញ្ជូនទៅផ្នែកសាធារណ: |
| ជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរ និងមានផលវិបាក | មាន | មាន | មាន | អាតេស៊ូណាតស៊ុល និង បញ្ជូន | |

**ហាមលក់ឱសថប្រឆាំងជំងឺគ្រុនចាញ់គ្រប់ប្រភេទ នៅក្នុងសេវាឯកជនក្រោយឆ្នាំ២០១៥

# 3. របៀបធ្វើរោគវិនិច្ឆ័យជម្ងឺគ្រុនចាញ់

វិធីតែមួយគត់ដើម្បីឲ្យប្រាកដថា អ្នកជម្ងឺម្នាក់មានជម្ងឺគ្រុនចាញ់ពិតប្រាកដ បើគាត់មានតេស្តឈាមវិជ្ជមាន"ហៅថាជម្ងឺគ្រុនចាញ់សន្និដ្ឋានឬត្រូវបានបញ្ជាក់"។ រាល់ករណីជម្ងឺគ្រុនចាញ់សង្ស័យទាំងអស់គួរទទួលការធ្វើរោគវិនិច្ឆ័យរកមេរោគគ្រុនចាញ់ មុនពេលព្យាបាលនៅ គ្រប់មូលដ្ឋានផ្តល់សេវា សុខភាពទាំងអស់។

**ការព្យាបាលជម្ងឺគ្រុនចាញ់មិនត្រូវចាប់ផ្តើមភ្លាមទេ លុះត្រាតែរោគវិនិច្ឆ័យត្រូវបានបញ្ជាក់តាមរយៈការពិនិត្យរកមេរោគគ្រុនចាញ់ក្នុងឈាមជាមុនសិន។**

## 3.1 ប្រវត្តិអ្នកជម្ងឺ

- ***កត្តាប្រឈមនឹងគ្រោះថ្នាក់នៃជម្ងឺគ្រុនចាញ់៖***
  - អ្នកទៅតាំងទីលំនៅថ្មីក្នុងតំបន់ចម្លងជម្ងឺគ្រុនចាញ់
  - រស់នៅ ឬប្រកបការងារក្នុងព្រៃ
  - ស្ត្រីមានផ្ទៃពោះ
  - កុមារ
  - មិនដេកក្នុងមុងជ្រលក់ថ្នាំនៅក្នុងតំបន់ដែលចម្លងគ្រុនចាញ់ខ្ពស់
  - មិនព្រម ឬពន្យារពេលស្វះស្វែងរកការថែទាំសុខភាព
  - ការធ្វើរោគវិនិច្ឆ័យខុស
- ***ប្រវត្តិជម្ងឺ និង ឱសថ៖***
  - ធ្លាប់មានប្រវត្តិកើតជម្ងឺគ្រុនចាញ់ពីមុន
  - តើខែមុនបានប្រើឱសថគ្រុនចាញ់អ្វីខ្លះ? (ឧទា. អាតេស៊ូណាត មេហ្លូគីន (eg: Artesunate, Mefloquine, DHA-PIP)
  - តើមានកើតជម្ងឺដទៃទៀត ឬធ្លាប់មានប្រតិកម្មថ្នាំអ្វីខ្លះ?

- ប្រវត្តិមានជម្ងឺទូទៅ និងជម្ងឺរ៉ះកាត់ដទៃទៀត

## 3.2 លក្ខណៈនៃជម្ងឺគ្រុនចាញ់ស្រាល

❖ ***រោគសញ្ញានៃជម្ងឺគ្រុនចាញ់ស្រាល***

| គ្រុនក្តៅ - រងារញាក់ - បែកញើស |
|---|

❖ ***រោគសញ្ញាផ្សេងៗដែលតែងជួបប្រទះ៖*** ឈឺក្បាល ឈឺខ្នងចង្កេះ ឬឈឺសាច់ដុំ ឈឺពោះ (ចង់ក្អួតចង្អោរ ក្អួត រាក) ហើមពោះ ធ្លាក់អណ្តើក ឬថ្លើមរីកធំ។

## 3.3 និយមន័យជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរ ឬមានផលវិបាក[1]

គឺមានសញ្ញានៃជម្ងឺគ្រុនចាញ់ស្រាល និងបន្ថែមសញ្ញាណាមួយ ឬក៏ ច្រើន ក្នុងចំណោមសញ្ញាដូចខាងក្រោម៖

[1] ជំងឺគ្រុនចាញ់ហ្វាល់ស៊ីប៉ារ៉ូមធ្ងន់ធ្ងរ។ ប្រតិបត្តិការរបស់រាជសង្គមវេជ្ជសាស្ត្រត្រូពិតចនិងអនាម័យ (២០០០) ៩៤ ទំព័របន្ថែម១ (*Transactions of the Royal Society of Tropical Medicine and Hygiene* (2000) **94**, supplement 1)

- **អស់កម្លាំងខ្លាំង** (មិនអាចដើបអង្គុយ ឬផឹកទឹកបានឡើយ)
- **វិបត្តិស្មារតី** (សរុបពិន្ទុសន្លប់ Glasgow ≤ 9 ចំពោះមនុស្សពេញវ័យ និងកុមារអាយុលើសពី 5 ឆ្នាំ ឬពិន្ទុសន្លប់ Blantyre ≤ 2 ចំពោះកុមារដែលមិនទាន់ចេះនិយាយ)
- **ពិបាកដកដង្ហើម** (ច្រមុះបិទបើកជាប់, ចន្លោះឆ្អឹងជំនីផតប៉ោង, ដកដង្ហើមញាប់លើសពី 25ដងក្នុង១នាទី ចំពោះមនុស្សពេញវ័យ និងលើសពី 40ដងក្នុង១នាទី ចំពោះកុមារ)
- **ប្រកាច់ច្រើនដង** (លើសពី 1ដងក្នុង 24 ម៉ោង)
- **របត់ឈាមធ្លាក់ចុះ** គឺមានសញ្ញាដូចជាសម្ពាធឈាមទាបជាង < 50 mmHg ចំពោះកុមារអាយុតិចជាង 5 ឆ្នាំ ឬសម្ពាធឈាមទាបជាង <80 mmHg ចំពោះកុមារអាយុលើសពី 5 ឆ្នាំឡើងទៅ, ត្រជាក់ចុងដៃជើង និងជីពចរខ្សោយ
- **ហើមសួត** (សញ្ញាវិទ្យុសាស្ត្រ)
- **ការហូរឈាមខុសធម្មតា**
- **លឿង**
- **ទឹកនោមពណ៌ទឹកតែចាស់មើលដោយភ្នែកទទេ (haemoglobinuria)**
- **ស្លេកស្លាំងខ្លាំង** (Hb<5g/dl or Ht<15 %)
- **ជាតិស្ករក្នុងឈាមថយចុះ** (ជាតិស្ករក្នុងឈាមតិចជាង < 2.2 mmol/l or < 0.4 g/l)
- **អាស៊ីដូមេតាបូលិក** (ផ្លាស្មា ប៊ីកាបូណាត < 15 mmol/l)

- **ឡាក់តាតក្នុងឈាមឡើងខ្ពស់ (Hyperlactaemia)** (ផ្លាស្មា ឡាក់តាត ខ្ពស់ជាង > 5 mmol/l)
- **មេរោគក្នុងឈាមកើនឡើង** (*ផ្លា. ហ្វាល់ស៊ីប៉ារ៉ូម P.falciparum.++++ or* >200 000 parasites/µl)
- **ខ្សោយតម្រងនោម *ឬនោមតិច (oliguria)*** (បរិមាណទឹកនោមតិចជាង< 400ម.ល/24 ម៉ោង ឬផ្លាស្មា ក្រេអាទីនីនធំជាង> 265 µmol/l ចំពោះ មនុស្សពេញវ័យ ឬបរិមាណទឹកនោមតិចជាង < 12 ម.ល/គ.ក/24ម៉ោង ឬ ផ្លាស្មា ក្រេអាទីនីនលើសពីកម្រិតធម្មតា ទៅតាមអាយុ ហើយនៅ តែស្ថិតនៅនឹងបន្ទាប់ពី បានបំពេញជាតិ ទឹកឡើងវិញចំពោះកុមារ)
- **ក្អួតញឹកញាប់** (ក្អួតចេញអស់ពីពោះដោយគ្មានសល់អាហារឬថ្នាំ ឡើយ)

**បើអ្នកពិនិត្យឃើញមានសញ្ញាណាមួយនៃសញ្ញាទាំងឡាយដូចខាងលើ៖**

- **ជានិច្ចជាកាល ត្រូវជោះឈាម (ផ្ទៃស្តើង និងក្រាស់)ឬធ្វើតេស្តរហ័ស (RDT)**
- **ចាប់ផ្តើមធ្វើការព្យាបាលជាបន្ទាន់ ទោះជាមិនទាន់បានលទ្ធ ផលពិនិត្យ ឈាមក៏ដោយ។**

**ត្រូវចងចាំ៖**

- អាចមានចំពោះអ្នកជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរម្នាក់ដែលពិនិត្យកញ្ចក់ឈាមឬធ្វើតេស្តរហ័សទៅឃើញអវិជ្ជមានហើយបើមានសញ្ញាគ្លីនិកគួរឲ្យសង្ស័យខ្លាំងថាជាជម្ងឺគ្រុនចាញ់ទោះបីកញ្ចក់ឈាមឬធ្វើតេស្តរហ័សឃើញអវិជ្ជមានក៏ដោយ ក៏គួរតែព្យាបាលជម្ងឺគ្រុនចាញ់ដែរ។
- អ្នកជម្ងឺម្នាក់កើតជម្ងឺគ្រុនចាញ់ក៏អាចមានជម្ងឺមួយផ្សេងទៀតរួមផ្សំក្នុងពេលជាមួយគ្នាដែរ។

## 3.4. ជំរុះចោលជម្ងឺដទៃទៀត៖

**រោគសញ្ញានៃជម្ងឺគ្រុនចាញ់មានលក្ខណៈស្រដៀងគ្នានឹងជម្ងឺជាច្រើន ដែលបង្កឡើងដោយមេរោគ ជាពិសេសចំពោះកុមារ។ វាអាចមានជម្ងឺគ្រុនចាញ់រួម ផ្សំជាមួយជម្ងឺមួយផ្សេងទៀតនៅក្នុងពេលតែមួយ។**

❖ ជម្ងឺគ្រុនចាញ់ស្រាល៖ ត្រូវជំរុះចោលជម្ងឺដទៃទៀតដូចជា៖

- ជម្ងឺបង្កឡើងដោយវីរុស (ផ្តាសាយធំ ឬគ្រុនក្តៅ កញ្ជ្រឹល គ្រុនឈាម)
- ជម្ងឺបង្កឡើងដោយបាក់តេរី (ត្រចៀក បំពង់ក ឬទ្រូង)។

❖ ជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរ ឬមានផលវិបាក៖ ត្រូវជំរុះចោលជម្ងឺដទៃទៀតដូចជា៖

- រលាកស្រោមខួរ ឬរលាកខួរក្បាល
- គ្រុនពោះវៀន
- ការវាយលុករបស់មេរោគនៅក្នុងឈាម (សិបទីសេមី)
- រលាកសួតធ្ងន់ធ្ងរ
- គ្រុនឈាម (ចំពោះកុមារ)
- អេក្លំស៊ី (ព្រាយក្រឡាភ្លើងចំពោះស្ត្រីមានផ្ទៃពោះ)

## 3.5. ការធ្វើរោគវិនិច្ឆ័យជម្ងឺគ្រុនចាញ់

### 3.5.1 ការពិនិត្យកញ្ចក់ឈាមដោយមីក្រូទស្សន៍៖

**ការធ្វើរោគវិនិច្ឆ័យពិតប្រាកដ គឺពឹងផ្អែកលើការពិនិត្យកញ្ចក់ឈាមប៉ុណ្ណោះ ដែលជាបច្ចេកទេសមួយប្រកបដោយស្តង់ដារល្អសម្រាប់កំណត់រោគវិនិច្ឆ័យជម្ងឺគ្រុនចាញ់។**

### 3.5.2. ការពិនិត្យឈាមដោយធ្វើតេស្តរហ័ស (RDT):

តេស្តរហ័សអាចធ្វើរោគវិនិច្ឆ័យរកមេរោគ*ផ្លា.ហ្វាល់ស៊ីប៉ារ៉ូម*និងមេរោគគ្រុនចាញ់ប្រភេទដទៃទៀត រួមទាំង *ផ្លា. វីវ៉ាក់* ដែរ។
ជាការសំខាន់ ត្រូវប្រើតេស្តវិនិច្ឆ័យរហ័សណា ដែលអាចកំណត់បាន ពីភាពខុសគ្នានៃមេរោគគ្រុនចាញ់ *ផ្លា. ហ្វាល់ស៊ីប៉ារ៉ូម* និង *ផ្លា. វីវ៉ាក់*។ ការប្រើតេស្តវិនិច្ឆ័យរហ័សសម្រាប់កំណត់រកតែ*ផ្លា.ហ្វាល់ស៊ីប៉ារ៉ូម*មិនត្រូវណែនាំ នោះទេ។

**<u>ត្រូវចងចាំ៖</u>**

- ជួនកាលការជោះឈាមស្តើង-ក្រាស់អាចឃើញអវិជ្ជមាននៅពេលដែលមានគ្រុនចាញ់ធ្ងន់ធ្ងរ។
- ក្នុងករណីធ្ងន់ធ្ងរ ការពិនិត្យគំនៀសឈាម គឺជាវិធីល្អប្រសើរជាងការតេស្ត រោគវិនិច្ឆ័យរហ័ស ដោយហេតុថា វាមានគុណ ប្រយោជន៍បន្ថែម មិនត្រឹមតែរកឃើញមេរោគប៉ុណ្ណោះទេ ប៉ុន្តែថែម ទាំងអាចត្រូវបានគេប្រើដើម្បីកំណត់រោគវិនិច្ឆ័យរកជម្ងឺដទៃទៀតឬកំណត់ ពីទំហំនៃភាពធ្ងន់ធ្ងររបស់ជម្ងឺ គ្រុនចាញ់ផងដែរ។

## 3.6 សង្ខេប

**រោគវិនិច្ឆ័យពិតប្រាកដអាចធ្វើឡើងដោយផ្អែកលើការពិនិត្យកញ្ចក់ឈាម ឬតេស្តរ៉ាវិនិច្ឆ័យរហ័សតែប៉ុណ្ណោះ ។**

ប្រសិនបើមិនអាច ធ្វើការពិនិត្យកញ្ចក់ឈាម ឬ តេស្តវិនិច្ឆ័យរហ័សបាន ចូរបញ្ជូន អ្នកជម្ងឺទៅមូលដ្ឋានសុខាភិបាលសាធារណៈណា ដែលនៅជិតបំផុត ដែលអាចធ្វើរោគវិនិច្ឆ័យបាន។

ការព្យាបាល ដែលពឹងផ្អែកទៅលើការសង្ស័យ តែមួយមុខ គួរត្រូវបាន ពិចារណាតែនៅពេលណា ដែលរោគវិនិច្ឆ័យប៉ារ៉ាស៊ីតសាស្ត្រ មិនអាចធ្វើទៅបានតែប៉ុណ្ណោះ[2]។

[2] មគ្គុទ្ទេសក៍សម្រាប់ព្យាបាលជំងឺគ្រុនចាញ់ - បោះពុម្ពលើកទី២ អង្គការសុខភាពពិភពលោក ឆ្នាំ២០១០។

# 4. ការព្យាបាលជម្ងឺគ្រុនចាញ់ស្រាលចំពោះមនុស្សពេញវ័យ

## 4.1. គោលការណ៍

សេចក្ដីណែនាំរបស់កម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់ចំពោះមេរោគគ្រុនចាញ់ *ផ្លា. ហ្វាល់ស៊ីប៉ារ៉ូម ផ្លា. វីវ៉ាក់ ឬ ផ្លា. ម៉ាឡារីយេ* មានដូចខាងក្រោម៖

**ការព្យាបាលជម្រើសទី១៖**

-ឌីអ៊ីដ្រូអាតេមីស៊ីនីន-ពីពេរ៉ាគីន (DHA-PIP) + ព្រីម៉ាគីន (Primaquine)*

ឬ

-អាតេស៊ុយណាត + មេហ្វ្លូគីន (A+M) + ព្រីម៉ាគីន (Primaquine) *

**ការព្យាបាលជម្រើសទី២៖**

**-គីនីន + ដុកស៊ីស៊ីគ្លីន / តេត្រាស៊ីគ្លីន + ព្រីម៉ាគីន (Quinine + Doxycycline / Tetracycline + Primaquine) ***

កម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់ណែនាំប្រើប្រាស់ **អាតូវ៉ាកូន-ប្រូកានីល** *Atovaquone-proguanil* ឬ **អាតេមីស៊ីនីន-ពីរ៉ូណារីឌីន** Artesunate-Pyronaridine ដោយសង្កេតមើលផ្ទាល់ *(Directly Observed Treatment)* ជាមួយការតាមដានយ៉ាងតឹងរឹងក្នុងពេល ២៨ ថ្ងៃសម្រាប់ **ផ្លា.ហ្វាល់ ស៊ីប៉ារ៉ូម**ក្នុងខេត្តប៉ៃលិន និងតំបន់ដទៃទៀតនៅភាគខាងលិចប្រទេស កម្ពុជា ដែលមានភាពស៊ាំ និង *ACT* (*សូមមើលតារាងលេខ១ទំព័រទី9នឹងស្នើសេចក្ដីណែនាំពិសេសពី* មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់)

## 4.2. ការព្យាបាលយោងតាមលទ្ធផល ពិនិត្យឈាមស្លើង-ក្រាស់ ឬ តេស្តរិនិច្ឆ័យរហ័ស

### 4.2.1. លទ្ធផលកញ្ចក់ឈាមស្តើង-ក្រាស់ ឬ តេស្តវិនិច្ឆ័យរហ័សវិជ្ជមាន

❖ **ជំរើសទី១សម្រាប់ព្យាបាលជម្ងឺគ្រុនចាញ់ប្រភេទ** *ផ្លា. ហ្វាល់ស៊ីប៉ារ៉ូម ផ្លា. វីវ៉ាក់ ផ្លា. ម៉ាឡារីយេ ឬការឆ្លងមេរោគចម្រុះគ្នា៖*

- ឌីអ៊ីដ្រូអាតេមីស៊ីនីន + ពីពេរ៉ាគីន (DHA-PIP) សម្រាប់ព្យាបាល ៣ថ្ងៃ៖ ឌីអ៊ីដ្រូអាតេមីស៊ីនីន dihydroartemisinin (DHA) 40 ម.ក្រ/គ្រាប់ និង ពីពេរ៉ាគីន piperaquine (PIP) 320 ម.ក្រ/គ្រាប់។
- ថ្នាំព្រីម៉ាគីន Premaquine:
    - ផ្លា.ហ្វាល់ស៊ីប៉ារ៉ូម,ផ្លា.ម៉ាឡារីយេៈឲ្យលេបតែមួយដូស៨៥ម.ក្រ
    - ផ្លា.វីវ៉ាក់, ផ្លា.អូវ៉ាឡេៈ ៨៥ម.ក្រ/សប្តាហ៍ ចំនួន ៨សប្តាហ៍

**ឬ**

- អាតេស៊ុយណាត៥០ម.ក្រ+ម៉េហ្វ្លូគីន២៥០ម.ក្រ(A+M)
- ព្រីម៉ាគីន Premaquine:
    - ផ្លា.ហ្វាល់ស៊ីប៉ារ៉ូម,ផ្លា.ម៉ាឡារីយេៈឲ្យលេបតែមួយដូស៨៥ម.ក្រ
    - ផ្លា.វីវ៉ាក់, ផ្លា.អូវ៉ាឡេៈ ៨៥ម.ក្រ/សប្តាហ៍ ចំនួន ៨សប្តាហ៍

ថ្នាំព្រីម៉ាគីន ត្រូវបានណែនាំឲ្យប្រើប្រាស់ដោយ អង្គការសុខភាពពិភព លោក។ នៅក្នុងប្រទេសកម្ពុជា ថ្នាំព្រីម៉ាគីនត្រូវបានណែនាំសម្រាប់ព្យាបាលលើ អ្នកដែលមានភាពចុះខ្សោយនៃសារធាតុ **G6PD** ដរាបណា លទ្ធផលនៃការសិក្សាថ្នាំព្រីម៉ាគីនបានបង្ហាញថាមានសុវត្ថិភាពក្នុងការប្រើ។

(សូមមើលតារាងលេខ១ទំព័រទី9 នឹងស្នើសេចក្តីណែនាំពិសេសពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់)

### កាលវិភាគសម្រាប់ DHA-PIP (40 mg/320mg)

| ទម្ងន់ (គក) | អាយុ (ឆ្នាំ) | ចំនួនគ្រាប់<br>ឌីអ៊ីដ្រូអាតេមីស៊ីនីន - ពីពេរ៉ាគីន<br>Dihydroartemisinin-Piperaquine | | | |
|---|---|---|---|---|---|
| | | ថ្ងៃទី១ | ថ្ងៃទី២ | ថ្ងៃទី៣ | សរុប |
| 40គ.ក្រ ដល់ 79គ.ក្រ | > ១៥ឆ្នាំ | ៣គ្រាប់ | ៣គ្រាប់ | ៣គ្រាប់ | ៩គ្រាប់ |
| > ៨០គ.ក្រ | | ៤គ្រាប់ | ៤គ្រាប់ | ៤គ្រាប់ | ១២គ្រាប់ |

### កាលវិភាគសម្រាប់ A+M5

| ទម្ងន់ (គក) | អាយុ (ឆ្នាំ) | ចំនួនគ្រាប់ថ្នាំ | | | | | |
|---|---|---|---|---|---|---|---|
| | | អាតេស៊ុយណាត (50 ម.គ្រ) | | | មេហ្វ្លគីន (250 ម.គ្រ) | | |
| | | ថ្ងៃទី១ | ថ្ងៃទី២ | ថ្ងៃទី៣ | ថ្ងៃទី១ | ថ្ងៃទី២ | ថ្ងៃទី៣ |
| > ៤០គ.ក្រ | > ១៥ឆ្នាំ | ៤គ្រាប់ | ៤គ្រាប់ | ៤គ្រាប់ | ២គ្រាប់ | ២គ្រាប់ | ១គ្រាប់ |

សេចក្តីណែនាំ៖

- ផ្តល់កម្រិតថ្នាំទៅតាមទម្ងន់។ បើគ្មានជញ្ជីងទេចូរធ្វើការព្យាបាលតាមកំរិតអាយុ។
- សំខាន់បំផុតត្រូវឲ្យថ្នាំតាមកំរិតត្រឹមត្រូវ(បើសិនការព្យាបាលមិន ពេញលេញ អ្នកជម្ងឺអាចឈឺឡើងវិញ)
- ត្រូវពន្យល់អ្នកជម្ងឺអំពី៖
    - មូលហេតុនៃជម្ងឺគ្រុនចាញ់ និងវិធានការការពារ

- អត្ថប្រយោជន៍នៃការលេបថ្នាំគ្រប់ចំនួន និង គ្រប់ថ្ងៃព្យាបាល
- ផលរំខាន (ផលរំខានទូទៅរួមមានស្លេកស្លាំងឈឺក្បាលបេះដូង ដើរខុសធម្មតា)
- សារៈសំខាន់នៃការឆាប់ចូលមករកការព្យាបាលជាមួយ គ្រូពេទ្យ មុនពេលដំណាក់កាលគ្រុនចាញ់ វិវត្តទៅរកភាពធ្ងន់ធ្ងរ។

*ផលរំខានរបស់ថ្នាំ* (ឌីអ៊ីដ្រូអាតេមីស៊ីនីន+ពីពេរ៉ាគីន (*DHA-PIP*))
ជាទូទៅពុំសូវមានផលរំខានកើតឡើងទេ។ ភាគច្រើននៃផលរំខានគឺដោយ សារតែ ពីពេរ៉ាគីន ធ្វើឲ្យប៉ះពាល់ដល់ផ្លូវរំលាយអាហារ (ចង់ក្អួត រាក អត់ ឃ្លាន អាហារ ។ល។ ប្រតិកម្មអាឡែរហ្ស៊ីស្បែក (កន្ទួលលើស្បែក រមាស់ កន្ទាល ត្រអាក) ក៏ត្រូវបានគេរាយការណ៍ឲ្យដឹងផងដែរថាកម្រកើត មាន ។

**ចំណុចសំខាន់នៃការព្យាបាលដោយថ្នាំអាតេស៊ុយណាត+មេហ្លូគីន(A+M) ឬ ឌីអ៊ីដ្រូអាតេមីស៊ីនីន+ពីពេរ៉ាគីន (*DHA-PIP*)**

1. ភាពស៊ាំនឹងថ្នាំមេហ្លូគីន (Mefloquine) តែមួយមុខកើតមានហើយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
2. ដើម្បីឲ្យការព្យាបាលមានប្រសិទ្ធិភាព និងដើម្បីបញ្ឈប់ការរីករាល ដាលភាពស៊ាំនេះ ត្រូវឲ្យលេបថ្នាំ A+M ឬ DHA = PIP កំរិតត្រឹមត្រូវតាមទំងន់របស់អ្នកជម្ងឺ។
3. ត្រូវពិនិត្យមើលអ្នកជម្ងឺលេបថ្នាំគ្រាដំបូងនៅថ្ងៃទី ១ ហើយតាមដាន ក្នុងរយះពេលមួយម៉ោងបន្ទាប់ពីលេបថ្នាំរួច។
4. ដើម្បីជៀសវាងការក្អួតបន្ទាប់ពីលេបថ្នាំ ១ កំរិតដំបូង៖
   - ត្រូវបញ្ចុះកំដៅខ្លួនអ្នកជម្ងឺដោយគ្របកន្សែងទទឹក និង ឲ្យលេប ថ្នាំប៉ារ៉ាសេតាម៉ុល (Paracetamol) រយះពេល ៣០ ទៅ ៦០ នាទីមុននឹងឲ្យលេបថ្នាំគ្រុនចាញ់, និងអោយសមាជិកគ្រួសារ បក់ឲ្យអ្នកជម្ងឺ

➢ ត្រូវឲ្យអ្នកជម្ងឺសំរាកពី៣០ទៅ៦០នាទីមុននឹងធ្វើការព្យាបាល (ជាពិសេសកុមារអាយុក្រោម៥ឆ្នាំ)

➢ ត្រូវប្រាកដថាកុមារមានអារម្មណ៍ស្ងប់និងមិនភ័យខ្លាចនៅពេលដែលលេបថ្នាំ។

5. ប្រសិនបើអ្នកជម្ងឺបានលេបថ្នាំគីនីន (Quinine) រួចហើយត្រូវរង់ចាំ រយៈពេល១២ម៉ោងក្រោយពីលេបថ្នាំគីនីនដូសចុងក្រោយមុននឹងផ្តល់ថ្នាំ $A+M_5$ (Artesunate + Mefloquine) ទៅដល់អ្នកជម្ងឺ។

**ការហាមប្រើ៖**

មិនត្រូវផ្តល់មេហ្វ្លូគីន (**Mefloquine**) ចំពោះ៖

- អ្នកជំងឺដែលបានប្រើប្រាស់ថ្នាំមេហ្វ្លូគីនក្នុងអំឡុងពេល ៤ សប្តាហ៍កន្លងមក។
- អ្នកជំងឺដែលមានប្រវត្តិប្រតិកម្មអាឡែរហ្ស៊ីជាមួយថ្នាំមេហ្វ្លូគីន
- អ្នកជំងឺដែលកំពុងប្រើថ្នាំឌីហ្កុកស៊ីន (**digoxine**) ឬ បេតាប្លូកកង់ (**β-bloquant)**
- អ្នកជំងឺដែលមានបញ្ហាបេះដូង
- អ្នកជំងឺឆ្កួតជ្រូក ប្រកាច់
- អ្នកជំងឺមានបញ្ហាសរសៃប្រសាទ
- អ្នកមានជំងឺតំរងនោម ឬ ថ្លើម

អ្នកជំងឺទាំងអស់នោះគួរតែទទួលការព្យាបាលជាមួយនឹងថ្នាំ គីនីន + ដុកស៊ីស៊ីគ្លីន / តេត្រាស៊ីគ្លីន ក្នុងរយៈពេល ៧ ថ្ងៃ។

*<u>ចំពោះស្ត្រីមានផ្ទៃពោះ</u>*

- គីនីនមានសុវត្ថិភាពសម្រាប់ព្យាបាលលើស្ត្រីមានផ្ទៃពោះគ្រប់ត្រីមាសទាំងអស់នៃការមានគត៌។

- A+Mមានសុវត្ថិភាពសម្រាប់តែការព្យាបាលលើស្ត្រីមានផ្ទៃពោះក្នុងត្រីមាសទី២ និងទី៣។
- DHA-PIP មានសុវត្ថិភាព សម្រាប់តែការព្យាបាល លើស្ត្រីមាន ផ្ទៃពោះក្នុងត្រីមាសទី២និងទី៣។ប៉ុន្តែសុវត្ថិភាពនៃថ្នាំនេះលើស្ត្រីមានផ្ទៃពោះក្នុងត្រីមាសទី១ពុំទាន់ដឹងច្បាស់នៅឡើយទេ។

### 4.2.2. លទ្ធផលកញ្ចក់ឈាមស្តើង-ក្រាស់ ឬ តេស្តវិនិច្ឆ័យរហ័សអវិជ្ជមាន៖

- ប្រសិនបើលទ្ធផលតេស្តវិនិច្ឆ័យរហ័ស អវិជ្ជមាន ហើយមានរោគ សញ្ញាគ្លីនិកប្រាកដជាជម្ងឺគ្រុនចាញ់មែន ត្រូវធ្វើតេស្តសារជាថ្មីឬរកមើលជម្ងឺផ្សេងៗទៀតតាមពិធីសារណែនាំ (មើលតារាងស្តីពីការសម្រេចចិត្តនៅលើទំព័រ 9-10) .
- ប្រសិនបើលទ្ធផលតេស្តវិនិច្ឆ័យរហ័សអវិជ្ជមាន ហើយគ្មានរោគ សញ្ញាគ្លីនិកនៃជម្ងឺគ្រុនចាញ់ទេ មិនត្រូវព្យាបាលដូចជម្ងឺគ្រុនចាញ់ ទេតែត្រូវរកមើលជម្ងឺមួយផ្សេងទៀត។
- ប្រសិនបើរោគសញ្ញានៅតែមានត្រូវស្នើសុំធ្វើតេស្តវិនិច្ឆ័យរហ័ស ឬ កញ្ចក់ឈាមម្តងទៀត។

### 4.2.3. បើមិនអាចធ្វើតេស្ត វិនិច្ឆ័យរហ័ស និង/ឬ កញ្ចក់ឈាមស្តើង-ក្រាស់ បាន៖

- បើមិនអាចទទួលលទ្ធផលតេស្តវិនិច្ឆ័យរហ័ស ឬកញ្ចក់ឈាម ក្នុងថ្ងៃតែមួយទេ ត្រូវឲ្យអ្នកជម្ងឺសម្រាកក្នុងមន្ទីរពេទ្យ និងតាមដាន អ្នកជម្ងឺដើម្បីរង់ចាំលទ្ធផល។
- បើមិនអាចទទួលលទ្ធផលតេស្តវិនិច្ឆ័យ ឬកញ្ចក់ឈាម ត្រូវបញ្ជូន អ្នកជម្ងឺដោយផ្អែកលើសញ្ញានិងរោគសញ្ញាគ្លីនិក។

**ក្នុងករណីជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរឬមានផលវិបាក ត្រូវចាប់ផ្តើមព្យាបាលដោយប្រើ អាតេស៊ូណាត តាមសរសៃ (ឬអាតេមេទែរ តាមសាច់ដុំ) និង DHA-PIP**
(មើលមគ្គុទ្ទេសក៍សម្រាប់ព្យាបាលជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរ ទំព័រ 30 ដល់ 48)

## 4.3. ការតាមដានជម្ងឺគ្រុនចាញ់ស្រាលៈ

**4.3.1.**ការព្យាបាលជម្រើសទី១មិនទទួលបានជោគជ័យដោយប្រើថ្នាំDHA-PIPៈ បើសិនអ្នកជម្ងឺវិលមកវិញ ដោយមានរោគសញ្ញា នោះបញ្ជាក់ថាអាចមាន ជម្ងឺវាផ្សេងមួយទៀត ឬ អ្នកជម្ងឺលេបថ្នាំមិនបានត្រឹមត្រូវ (ការជ្រាបនៃថ្នាំ មិនបានគ្រប់គ្រាន់ ឬព្យាបាលមិនគ្រប់ដូស)។

1) បើសង្ស័យថាអ្នកជម្ងឺលេបថ្នាំមិនបានត្រឹមត្រូវ ត្រូវព្យាបាលដោយថ្នាំ ឌីអ៊ីដ្រូអាតេមីស៊ីនីន+ពីពេរ៉ាគីន (DHA-PIP) ឬ A+M ម្តងទៀត។
2) បើសិនអ្នកជម្ងឺបានលេបថ្នាំDHA-PIPគ្រប់ចំនួន៣ថ្ងៃហើយៗវិលត្រលប់មកវិញមុនថ្ងៃទី២៨បន្ទាប់ពីការព្យាបាលចូរឲ្យគីនីន+ដុកស៊ីស៊ីគ្លីន/តេត្រាស៊ីគ្លីន (quinine+doxycycline/tetracycline)
3) ឲ្យថ្នាំព្រីម៉ាគីនមួយដូសទៀតប្រសិនបើរកឃើញថាមានផ្កា.ហ្វាល់ស៊ីប៉ារ៉ូម និងឲ្យថ្នាំព្រីម៉ាគីនមួយដូសរៀងរាល់សប្តាហ៍ ចំនួន ៨ សប្តាហ៍ បើរកឃើញថាមានផ្កា. វីវ៉ាក់។
4) បើអ្នកជម្ងឺវិលមកវិញនៅក្រោយថ្ងៃទី២៨ បន្ទាប់ពីព្យាបាល ត្រូវស្រាវជ្រាវរកមើលការបង្កមេរោគគ្រុនចាញ់ថ្មីមួយទៀត ហើយ ត្រូវព្យាបាលដោយប្រើថ្នាំ ឌីអ៊ីដ្រូអាតេមីស៊ីនីន+ពីពេរ៉ាគីន DHA-PIP(dihydroartemisinin+piperaquine) យោងតាម លទ្ធផល តេស្ត វិនិច្ឆ័យរហ័ស ឬ កញ្ចក់ឈាម។

**បើសិនរោគសញ្ញានៅតែមាន ទោះបីជាបានលេបថ្នាំ DHA-PIP (dihydroartemisinin+piperaquine) ឬ A+M គ្រប់ចំនួនថ្ងៃក៏ដោយ ហើយបើសិនអ្នកជម្ងឺមិនបានក្អួតចេញគ្រាប់ថ្នាំទេ នោះទើបអាចបញ្ជាក់ថា មេរោគស៊ាំនឹងថ្នាំព្យាបាលប្រាកដមែន។**

**ត្រូវកត់ត្រាការព្យាបាលមិនបានទទួលជោគជ័យដាក់ក្នុងសៀវភៅចុះបញ្ជី។ វាមានសារៈសំខាន់សម្រាប់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់បានដឹងពីករណីទាំងនោះ។**

### 4.3.2. ការត្រួតពិនិត្យតាមដានប៉ារ៉ាស៊ីតសាស្ត្រ៖

1) ចំពោះមណ្ឌលសុខភាពឬប៉ុស្តិ៍សុខភាពដែលគ្មានមីក្រូទស្សន៍ត្រូវ៖
   - តាមដានមើលភាពប្រសើរផ្នែកគ្លីនិក
   - ប្រសិនបើរោគសញ្ញានៅតែមានសូមបញ្ជូនអ្នកជម្ងឺទៅមន្ទីរពេទ្យបង្អែកដែលនៅជិតបំផុតដោយយោងតាមលទ្ធផលកញ្ចក់ឈាម គាត់នឹងត្រូវទទួលការព្យាបាលឬមិនព្យាបាលដោយថ្នាំ គីនីន +ដុកស៊ីស៊ី គ្លីន / តេត្រាស៊ីគ្លីន។

**<u>សម្គាល់៖</u> មិនត្រូវប្រើតេស្តវិនិច្ឆ័យរហ័ស សម្រាប់ធ្វើការតាមដានបន្ទាប់ពីការព្យាបាលទេ។ ជារឿយរឿយ តេស្តវិនិច្ឆ័យរហ័សនៅតែវិជ្ជមានរហូតដល់ថ្ងៃទី ១៤ទោះជាមេរោគទាំងអស់ត្រូវបានសម្លាប់អស់ហើយក៏ដោយ**

2) ចំពោះមន្ទីរពេទ្យបង្អែកនឹងមណ្ឌលសុខភាពដែលមានមីក្រូទស្សន៍ត្រូវ៖
   - ពិនិត្យឈាមនៅថ្ងៃទី៣ បន្ទាប់ពីការព្យាបាល ដើម្បី សន្និដ្ឋានពីភាពអវិជ្ជមានឬការថយចុះនៃមេរោគក្នុងឈាមប្រៀបធៀបទៅ នឹង ថ្ងៃចូលសម្រាកពេទ្យ (ថ្ងៃទី១)។

- បើមេរោគក្នុងឈាមថយចុះចាប់ពីថ្ងៃទី ១ ដល់ថ្ងៃទី ៣ ត្រូវបន្ត ពិនិត្យឈាមនៅថ្ងៃទី៧ ដើម្បីសន្និដ្ឋានពីភាពអវិជ្ជមានរបស់វា។
- បើមេរោគក្នុងឈាមមិនថយចុះសោះចាប់ពីថ្ងៃទី១ដល់ថ្ងៃទី៣ត្រូវបញ្ជូនអ្នកជម្ងឺទៅកាន់មន្ទីរពេទ្យដែលនៅជិតបំផុត ដើម្បីបន្តការព្យាបាលដោយប្រើគីនីន+ដុកស៊ីស៊ីគ្លីន/តេត្រាស៊ីគ្លីន (quinine+doxy cycline/tetracycline)

## 4.4. ការព្យាបាលជម្រើសទី២ ដោយថ្នាំ គីនីន ចំពោះ*ផ្លា. ហ្វាល់ស៊ីប៉ារ៉ូម*

### 4.4.1. ការព្យាបាល៖

*កំរិតថ្នាំ៖*

1) កំរិតថ្នាំគីនីន គឺ ១0 ម.ក្រ/គ.ក ចំនួន 3 ដង ក្នុង 24ម៉ោង (៣0ម.ក្រ/គ.ក / ថ្ងៃ)។
2) កំរិតថ្នាំដុកស៊ីស៊ីគ្លីន គឺលេបម្តង ១00 ម.ក្រ ចំនួន ២ដង ក្នុង 24 ម៉ោង សម្រាប់មនុស្សពេញវ័យ (លេបម្តង ២ ម.ក្រ/គ.ក ចំនួន ២ ដង ក្នុងមួយថ្ងៃ សម្រាប់កុមារលើស 8 ឆ្នាំ) ឬ តេត្រាស៊ីគ្លីន ៨.៣ ម.ក្រ/គ.ក ចំនួន ៣ ដង ក្នុង 24 ម៉ោង (25 ម.ក្រ/គ.ក / ថ្ងៃ។
3) **ការព្យាបាលដោយ គីនីន+ដុកស៊ីស៊ីគ្លីន ត្រូវតែប្រើឲ្យអស់គ្រប់ 7 ថ្ងៃ។**
4) បើអាចធ្វើទៅបានត្រូវព្យាបាលទៅតាមទម្ងន់អ្នកជម្ងឺ បើ មិន ដូច្នោះ ទេ ត្រូវព្យាបាលទៅតាមអាយុ។

*ហាមប្រើ៖*

មិនត្រូវប្រើថ្នាំដុកស៊ីស៊ីគ្លីន ឬ តេត្រាស៊ីគ្លីនចំពោះស្ត្រីមានផ្ទៃពោះ នឹងកុមារអាយុក្រោម ៨ឆ្នាំ

*ការណែនាំ៖*

1) ការប្រើថ្នាំគីនីនតាមកម្រិតត្រឹមត្រូវ ពុំបណ្តាល ឲ្យ មាន គ្រោះ ថ្នាក់ ដល់ ស្ត្រីមានផ្ទៃពោះឡើយ។
2) ចំពោះកុមារតូចៗត្រូវកិនគ្រាប់ថ្នាំឲ្យម៉ត់ល្អរួចលាយជាមួយទឹកសុទ្ធ ឬទឹកស្ករឲ្យផឹក។
3) ត្រូវពន្យល់អ្នកជម្ងឺអំពី៖
   - ផលរំខាននៃថ្នាំគីនីន (វិលមុខ ចង់ក្អួត ហ៊ឹងត្រចៀក)
   - សារៈសំខាន់នៃការព្យបាលត្រឹមត្រូវរយៈពេល៧ថ្ងៃ
   - មិនត្រូវប្រើថ្នាំគីនីនសម្រាប់បង្ការជម្ងឺគ្រុនចាញ់ឡើយ
   - ត្រូវប្រើឱសថប្រឆាំងនឹងជម្ងឺគ្រុនចាញ់បន្ទាប់ពីតេស្តរហ័សឬកញ្ចក់ឈាមវិជ្ជមានប៉ុណ្ណោះ
   - មូលហេតុ និងវិធានការបង្ការជម្ងឺគ្រុនចាញ់

**4.4.2. ការតាមដានផ្នែកប៉ារ៉ាសិតសាស្រ្តចំពោះ ថ្នាំគីនីន+ដុកស៊ីស៊ីគ្លីន/តេត្រាស៊ីគ្លីន៖**

1) ឲ្យអ្នកជម្ងឺត្រឡប់មកពិនិត្យឡើងវិញ នៅថ្ងៃទី ៣ និងថ្ងៃទី ៧ បន្ទាប់ពីទទួលការព្យាបាលដើម្បីត្រួតពិនិត្យមើលប្រសិទ្ធភាពនៃការព្យាបាល។
2) ត្រូវជោះឈាមយកទៅពិនិត្យ នៅថ្ងៃទី ៣ ដរាបណារោគសញ្ញានៅតែមាន ក៏ប៉ុន្តែចាំបាច់ត្រូវធ្វើកញ្ចក់ឈាមនៅថ្ងៃទី7។
3) កញ្ចក់ឈាមដែលវិជ្ជមាន នៅថ្ងៃទី ៣ ពុំមែនមានន័យថា មេរោគ ស៊ាំនឹង ថ្នាំព្យាបាលនោះទេ។ សំខាន់គឺត្រូវពិនិត្យរាប់មេរោគ នៅ ចន្លោះថ្ងៃទី១ និងថ្ងៃទី៣។ បើសិនការរាប់មេរោគនៅ ថ្ងៃទី៣ ឃើញខ្ពស់ជាងថ្ងៃទី១៖ត្រូវឲ្យអ្នកជម្ងឺសម្រាកក្នុងមន្ទីរពេទ្យហើយតាមដានយ៉ាង ប្រុង

ប្រយ័ត្នបំផុត។ត្រូវជោះឈាមយកទៅពិនិត្យនៅថ្ងៃទី៤ដើម្បីបញ្ជាក់ ពីការព្យាបាលមិនទទួលបានជោគជ័យហើយទាក់ទងមជ្ឈមណ្ឌល ជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់។

4) កញ្ចក់ឈាមដែលវិជ្ជមានមេរោគនៅថ្ងៃទី៧អាចមានន័យថាការព្យបាលមិនទទួលបានជោគជ័យ។

### 4.4.3. បរាជ័យនៃការព្យាបាលដោយថ្នាំ ថ្នាំគីនីន+ដុកស៊ីស៊ីគ្លីន /តេត្រាស៊ីគ្លីន (quinine+doxycycline/tetracycline):

1) បើកញ្ចក់ឈាមនៅតែវិជ្ជមានមេរោគគ្រុនចាញ់ (ត្រូហ្វូសូអ៊ីត trophozoites) នៅថ្ងៃទី៧ ត្រូវបន្តការព្យាបាលរហូតដល់ថ្ងៃទី១០។
2) បើកញ្ចក់ឈាមនៅតែវិជ្ជមានមេរោគគ្រុនចាញ់ (ត្រូហ្វូសូអ៊ីត trophozoites) នៅថ្ងៃទី ១០ ត្រូវបន្តការព្យាបាលរហូតដល់ថ្ងៃទី១៤។
3) បើកញ្ចក់ឈាមនៅតែវិជ្ជមានមេរោគគ្រុនចាញ់ (ត្រូហ្វូសូអ៊ីត trophozoites) នៅថ្ងៃទី១៤ទៀតត្រូវពិនិត្យមើលតើអ្នកជម្ងឺលេបថ្នាំគ្រប់កម្រិតនឹងគ្រប់ចំនួនថ្ងៃព្យាបាលត្រឹមត្រូវឬទេ។
4) បើបានលេបថ្នាំត្រឹមត្រូវហើយត្រូវបញ្ជូនទៅមន្ទីរពេទ្យកម្រិតខ្ពស់ មួយទៀត។

**<u>ត្រូវចងចាំ៖</u>**

**កញ្ចក់ឈាមដែលវិជ្ជមានតែហ្គាម៉េតូស៊ីត (gametocytes) ហើយបើគ្មានរោគសញ្ញា គ្លីនិកសំខាន់ៗទេនោះពុំអាចបញ្ជាក់ថាការព្យាបាលមិនទទួលបានជោគជ័យឡើយ។**

# 5. ការព្យាបាលជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរ ឬផលវិបាកចំពោះមនុស្សពេញវ័យ

## 5.1. មគ្គុទ្ទេសក៍ព្យាបាលផ្សេងៗសម្រាប់ជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផលវិបាក ព្យាបាល

### 5.1.1a. ការព្យាបាលជម្រើសទី១ ដោយថ្នាំអាតេស៊ូណាត (IV/IM) + ឌីអ៊ី ជ្រូ អាតេមីស៊ីនីន+ពីពេរ៉ាគីន (DHA-PIP) + ព្រីម៉ាគីន (Primaquine) :

ត្រូវព្យាបាលដោយអាតេស៊ូណាតតាមសរសៃ (Artesunate IV)។ បើគ្មាន អាតេស៊ូណាតត្រូវប្រើអាតេមេទែរតាមសាច់ដុំ (artemether IM)។ បន្ទាប់ មកឲ្យ DHA-PIP នៅពេលអ្នកជម្ងឺអាចលេបបាន នឹងព្រីម៉ាគីន មួយដូស។

**ប្រយ័ត្ន!**

មិនត្រូវច្រឡំអាតេស៊ូណាតដបតាមសរសៃ(IV) ជាមួយអាតេមេទែរអំពូលតាមសាច់ដុំ (IM) ឡើយ!

សូមអានស្លាកសញ្ញាឲ្យបានច្បាស់លាស់មុននឹងចាក់ឲ្យអ្នកជម្ងឺ។

*កម្រិតប្រើ៖*

ឲ្យអាតេស៊ូណាតតាមសរសៃ (artesunate IV) *2.4* ម.ក្រ/គ.ក តាមទំងន់ ខ្លួនអ្នកជម្ងឺ ដូចពេលខាងក្រោម៖

- ផ្តល់ដូសទីមួយក្នុងថ្ងៃចូលសម្រាកពេទ្យ
- 12 ម៉ោងក្រោយមក ផ្តល់ដូសទីពីរ
- 12 ម៉ោងបន្ទាប់មកទៀត ផ្តល់ដូសទីបី

- បន្តផ្តល់ការព្យាបាលរៀងរាល់24ម៉ោងម្តងរហូតដល់ដូសទី7(ដូសចុងក្រោយ)
- ឱ្យ DHA-PIP រយៈពេល 3 ថ្ងៃពេញនៅពេលអ្នកជម្ងឺអាចលេបបាន ព្រមទាំងឲ្យថ្នាំព្រីម៉ាគីន Primaquine

ឧទាហរណ៍៖ អាតេស៊ូណាតចាក់សរសៃ (IV)

| ទម្ងន់(គ.ក្រ) | ចំនួនដូសថ្នាំ/គ.ក្រ | កម្រិតថ្នាំសរុប (ម.ក្រ) | ចំនួនដប (60 ម.ក្រ) | សូដ្យូមប៊ីកាបូណាត (5%) | សេរ៉ូមប្រៃ/ដិចស្រ្តូ (5%) |
|---|---|---|---|---|---|
| 50 គ.ក្រ | 2.4 | 120 | 2 | 2 | 10 ម.ល* |
| 25 គ.ក្រ | 2.4 | 60 | 1 | 1 | 5 ម.ល |
| 12.5 គ.ក្រ | 2.4 | 30 | 0.5 | 0.5 | 2.5 ម.ល |

**កំណត់សម្គាល់៖* 60 ម.ក្រ IV + 1 ម.ល 5% សូដ្យូមប៊ីកាបូណាត + 5 ម.ល សេរ៉ូមប្រៃ ឬ ដិចស្រ្តូ (dextrose) 5% = 6 ម.ល

ឧទាហរណ៍៖ អាតេស៊ូណាតចាក់សាច់ដុំ (IM)

| ទម្ងន់(គ.ក្រ) | ចំនួនដូសថ្នាំ/គ.ក្រ | កម្រិតថ្នាំសរុប (ម.ក្រ) | ចំនួនដប (60 ម.ក្រ) | សូដ្យូមប៊ីកាបូណាត (5%) | សេរ៉ូមប្រៃ/ដិចស្រ្តូ (5%) |
|---|---|---|---|---|---|
| 50 គ.ក្រ | 2.4 | 120 | 2 | 2 | 4 ម.ល* |
| 25 គ.ក្រ | 2.4 | 60 | 1 | 1 | 2 ម.ល |
| 12.5 គ.ក្រ | 2.4 | 30 | 0.5 | 0.5 | 1 ម.ល |

**កំណត់សម្គាល់៖* 60 ម.ក្រ IM + 1 ម.ល 5% សូដ្យូមប៊ីកាបូណាត + 2 ម.ល សេរ៉ូមប្រៃ ឬ ដិចស្រ្តូ (dextrose) 5% = 3 ម.ល

### 5.1.1b. ការព្យាបាលជម្រើសទី១ ដោយថ្នាំអាតេមេទែរ (IM) + ឌីអ៊ីដ្រូអាតេមីស៊ីនីន +ពីពេរ៉ាគីន (DHA-PIP) + ព្រីម៉ាគីន (Primaquine)

*<u>កម្រិតប្រើ</u>*

| |
|---|
| **ថ្ងៃទី ១: (ថ្ងៃចូលសម្រាកពេទ្យ)**<br>ត្រូវឲ្យអាតេម៉េទែរ ៣.២ ម.ក្រ/គ.ក្រ (ចាក់សាច់ដុំ) |
| **ថ្ងៃទី ២:**<br>ត្រូវឲ្យអាតេម៉េទែរ ១.៦ ម.ក្រ/គ.ក្រ (ចាក់សាច់ដុំ) |
| **ថ្ងៃទី ៣ ដល់ថ្ងៃទី ៥:**<br>ត្រូវឲ្យអាតេម៉េទែរ ១.៦ ម.ក្រ/គ.ក្រ (ចាក់សាច់ដុំជារៀងរាល់ថ្ងៃ) |
| **ចាប់ពីថ្ងៃទី ៦:**<br>ត្រូវឲ្យឌីអ៊ីដ្រូអាតេមីស៊ីនីន+ពីពេរ៉ាគីន រយៈពេល 3 ថ្ងៃពេញ |

ការបញ្ចូលសេរ៉ូមតាមសរសៃ (intravenous fluid) គឺជាការចាំបាច់ នៅពេលព្យាបាលដោយអាតេមេទែរ (artemether IM) ចាក់សាច់ ដុំព្រោះថា ភាគច្រើននៃអ្នកជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរគាត់មិនអាចហូប ឬផឹកបានទេ ដូច្នេះ គាត់ត្រូវការចាក់បញ្ចូលសេរ៉ូមតាមសរសៃ (intravenous fluid) ។

***ការរក្សាលំនឹងជាតិទឹក៖***

ត្រូវចាក់បញ្ចូលសេរ៉ូមតាមសរសៃ ៥០០ ម.ល × ៣ ដង ក្នុង២៤ ម៉ោងគឺ ឲ្យសេរ៉ូមជិចស្ក្រូស ៥% ($D_{5\%}$) ចំនួន ២ដប ឬសេរ៉ូមជិចស្ក្រូស ១០% ($D_{10\%}$) បូកនឹងសេរ៉ូមប្រៃ០.៩%ចំនួន១ដប។

***សេចក្តីណែនាំ៖***

1) បើអ្នកមិនអាចថ្លឹងទម្ងន់អ្នកជម្ងឺបានទេ ត្រូវប៉ាន់ទម្ងន់អ្នកជម្ងឺ។

2) បើអ្នកជម្ងឺដឹងខ្លួនឡើងវិញ ហើយអាចលេបថ្នាំគ្រាប់បាន**មុន ថ្ងៃ ទី៥** នៃការព្យាបាលដោយថ្នាំអាតេសូណាតតាមសរសៃ ឬសាច់ដុំ (IV/IM) ឬ អាតេមេទែតាមសាច់ដុំ (IM) ចាំបាច់ត្រូវឲ្យលេបថ្នាំ DHA-PIPនិង ព្រីម៉ាគីនដោយឲ្យគាត់លេបថ្នាំដូសដំបូងនៅចំពោះមុខយើង។

***ឧទាហរណ៍៖***

ចំពោះអ្នកជម្ងឺម្នាក់ដែលមានទំងន់ ៥០ គ.ក្រ ត្រូវឲ្យ៖

**- ក្នុងថ្ងៃទី១: អាតេម៉េទែរ ៣.២ ម.ក្រ x ៥០ គ.ក្រ = ១៦០ ម.ក្រចាក់សាច់ដុំ**

**<u>កំណត់សម្គាល់:</u>**

ក្នុង១អំពូលមានអាតេម៉េទែរ ៨០ ម.ក្រ ដូច្នេះ ត្រូវចាក់សាច់ដុំចំនួន២ អំពូលចាក់តែមួយដង។

**- ចាប់ពីថ្ងៃទី២ដល់ថ្ងៃទី៥៖** អាតេម៉េទែរ១.៦ម.ក្រ x ៥០គ.ក្រ = ៨០ម.ក្រ ចាក់សាច់ដុំ គឺត្រូវចាក់ ១ អំពូលតែ ១ ដងជារៀងរាល់ថ្ងៃ។

*ក្នុងករណីនេះប្រើក្នុងមួយដូសត្រឹមតែមួយអំពូលសម្រាប់ថ្ងៃនីមួយៗ*

**- ចាប់ពីថ្ងៃទី ៦:** ឲ្យថ្នាំឌីអ៊ីដ្រូអាតេមីស៊ីនីន+ពីពេរ៉ាគីន (DHA-PIP) សម្រាប់ពេល ៣ ថ្ងៃ

### 5.1.2. អាតេស៊ូណាតស៊ុល មុនពេលបញ្ជូនអ្នកជម្ងឺទៅមន្ទីរពេទ្យបង្អែក៖

- ឲ្យថ្នាំអាតេស៊ូណាតស៊ុលតាមបាត ២០០ ម.ក្រ សម្រាប់ព្យាបាលមុនពេលបញ្ជូនអ្នកជម្ងឺទៅមន្ទីរពេទ្យបង្អែកដែលនៅជិតបំផុត។

| | អាយុ(ឆ្នាំ) | អាតេស៊ូណាតស៊ុល (ម.ក្រ) | ចំនួនស៊ុល |
|---|---|---|---|
| ≥40គ.ក្រ | >15ឆ្នាំ | 200 | 2 |

**មុនពេលបញ្ជូន ត្រូវបំពេញទំរង់បែបបទបញ្ជូនជម្ងឺ ដោយបញ្ជាក់ពីកម្រិតថ្នាំដែលបានផ្តល់ នឹងពេលវេលា។**

*ការរក្សាលំនឹងជាតិទឹក៖*

ឲ្យសេរ៉ូម500ម.ល × 3 ក្នុងពេល 24 ម៉ោង៖ ឲ្យសេរ៉ូមជិចស្ត្រូស dextrose 5% ឬ dextrose 10% ចំនួន 2 ដប បូកនឹងសេរ៉ូមប្រៃ 0.9% ចំនួន1ដប។

*ហាមប្រើ៖*

**មិនត្រូវប្រើថ្នាំ អាតេសូណាត (Artesunate) ឬ អាតេមេទែរ (Artemether) ចំពោះស្ត្រីមានគភ៌ក្នុងត្រីមាសទី១ទេ។** ដូច្នេះ ត្រូវចាក់ថ្នាំគីនីនតាមសរសៃ (IV Quinine) រួចបន្តដោយថ្នាំគ្រាប់ លេបតាមមាត់ ក្នុងករណី ដែលអ្នកជម្ងឺអាចលេបបានសម្រាប់រយៈពេល យ៉ាងតិច ៧ថ្ងៃ។

*សេចក្តីណែនាំ៖*

- បើពុំអាចថ្លឹងអ្នកជម្ងឺបាន ចូរប៉ាន់ស្មានទម្ងន់អ្នកជម្ងឺ។
- បើសិនមួយដូសថ្នាំតិចជាងមួយដប ថ្នាំដែលនៅសល់គួរបោះចោល បើមិនបានប្រើភ្លាមៗសម្រាប់អ្នកជម្ងឺម្នាក់ទៀតទេ។

[3] The use of antimalarial drugs Report of a WHO Informal Consultation. WHO, Geneva, 13-17 November 2000

- ត្រូវចងចាំថាថ្នាំដែលបានលាយទុកលើសពី ១ ម៉ោងពុំអាចប្រើ ប្រាស់បានទេ
- បរិមាណកម្រិតដូសគួរបង្គ្រប់ជាចំនួនគត់គិតជាម.ល (ឧទា. សម្រាប់កុមារដែលត្រូវការតែ ៤.៣ ម.ល គួរឲ្យដល់ ៥ ម.ល )
- ថ្នាំចាក់តាមសរសៃត្រូវចាក់យឺតៗ ពី ៤ ទៅ ៥ នាទី
- ថ្នាំបន្ទាប់ពីលាយរួចត្រូវចាក់ភ្លាម
- បោះចោលសូលុយស្យុងណាដែលមិនបានប្រើក្នុងអំឡុងពេល 1ម៉ោងក្រោយពេលលាយរួច
- ត្រូវរៀបចំសូលុយស្យុងថ្មី សម្រាប់ការចាក់ថ្នាំមួយលើកៗ
- បើអ្នកជម្ងឺដឹងខ្លួនឡើងវិញហើយអាចលេបថ្នាំគ្រាប់បាន**មុនថ្ងៃទី៥**នៃការព្យាបាលដោយថ្នាំអាតេសូណាតតាមសរសៃឬសាច់ដុំ(IV/IM) ឬអាតេមេទែតាមសាច់ដុំ (IM) ចាំបាច់ ត្រូវ ឲ្យ លេបថ្នាំ DHA-PIP និងព្រីម៉ាគីនដោយឲ្យគាត់លេបថ្នាំដូសដំបូង នៅ ចំពោះមុខយើង

### 5.1.3. ការព្យាបាលជម្រើសទី២ ដោយប្រើគីនីន (Quinine IV)+ ដុកស៊ីស៊ីលីន /តេត្រាស៊ីលីន៖

**កម្រិតថ្នាំ និងរបៀបព្យាបាល៖**

**ថ្ងៃទី១ (ថ្ងៃចូលសម្រាកពេទ្យ)**

• **ការបញ្ចូលសេរ៉ូមលើកទី១៖**

សេរ៉ូមដិចស្រ្តូស(10%) ចំនួន 500 ម.ល + គីនីន ឌីអ៊ីដ្រូក្លរីដចំនួន 10 ម.ក្រ/គ.ក្រ/ 4ម៉ោង (40ដំណក់/នាទី)

• **<u>ការបញ្ចូលសេរ៉ូមលើកទី២៖</u>**

សេរ៉ូមជិចស្រ្តូស (10%) ចំនួន 500 ម.ល + គីនីន ឌីអ៊ីដ្រូក្លរីដចំនួន 10 ម.ក្រ/គ.ក្រ/ 8ម៉ោង)(20ដំណក់/នាទី)

• **<u>ការបញ្ចូលសេរ៉ូមលើកទី៣៖</u>**

សេរ៉ូមជិចស្រ្តូស (10%) ចំនួន 500 ម.ល + គីនីន ឌីអ៊ីដ្រូក្លរីដចំនួន 10 ម.ក្រ/គ.ក្រ/ 8ម៉ោង)(20ដំណក់/នាទី)

**ថ្ងៃទី២**

**ចាក់បញ្ចូលសេរ៉ូម ៣ ដង ក្នុងចន្លោះពេល 8 ម៉ោងម្តង អនុវត្ត ដូចគ្នានឹងការបញ្ចូលសេរ៉ូមលើកទី៣នៃថ្ងៃទី១៖**

សេរ៉ូមជិចស្រ្តូស (10%) ចំនួន 500 ម.ល + គីនីន ឌីអ៊ីដ្រូក្លរីដចំនួន 10 ម.ក្រ/គ.ក្រ/ 8ម៉ោង)(20ដំណក់/នាទី)

**ពីថ្ងៃទី៣ដល់ថ្ងៃទី៧**

**<u>បើសិនអ្នកជម្ងឺដឹងខ្លួនឡើងវិញហើយអាចលេបថ្នាំគ្រាប់បាន៖</u>ត្រូវបញ្ឈប់ការបញ្ចូលសេរ៉ូមតាមសរសៃ**

• ឲ្យថ្នាំលេបគីនីន 10ម.ក្រ/គ.ក្រ x 3ដងក្នុងមួយថ្ងៃ (រៀងរាល់8ម៉ោងម្តង) ឱ្យបានគ្រប់7ថ្ងៃ។

•ឱ្យដុកស៊ីស៊ីគ្លីន 100ម.ក្រសម្រាប់មនុស្សពេញវ័យតែមួយម្តងក្នុងមួយថ្ងៃ (រៀងរាល់24ម៉ោង)

ឬតេត្រាស៊ីគ្លីន២៥មក្រ/គក្រចែកចេញជា៣ដងក្នុង២៤ម៉ោង។ ការ ព្យាបាលត្រូវឱ្យបានគ្រប់ចំនួន7ថ្ងៃ។(មើលតារាង *6a-b* ទំព័រទី71-72)

**<u>បើសិនអ្នកជម្ងឺមិនទាន់ដឹងខ្លួនពីសន្លប់៖</u>**

- ត្រូវបន្តចាក់សេរ៉ូម និងថ្នាំតាមសរសៃដូចបានអនុវត្ត ដូចគ្នា នឹងថ្ងៃទី២

*<u>សេចក្តីណែនាំ៖</u>*

បើពុំអាចថ្លឹងទម្ងន់អ្នកជម្ងឺបាន ចូរប៉ាន់ស្មានទម្ងន់របស់គាត់។

- ជានិច្ចជាកាលត្រូវចាក់សេរ៉ូមជិចស្រ្តូស ១០% ព្រោះគីនីនអាចធ្វើ ឲ្យជាតិស្ករក្នុងឈាមថយចុះ។
- បើមិនអាចរកបានដុកស៊ីស៊ីគ្លីន ចូរប្រើតេត្រាស៊ីគ្លីនជំនួស
- ដុកស៊ីស៊ីគ្លីន និងតេត្រាស៊ីគ្លីន មិនត្រូវប្រើចំពោះកុមារអាយុ ក្រោម8ឆ្នាំ។ ចូរប្រើគ្លីនដាមីស៊ីនជំនួស បើសិនជាមាន (ប្រើ 5ម.ក្រ/គ.ក្រក្នុងមួយថ្ងៃ)

**ដើម្បីលាយអោយបានសេរ៉ូមជិចស្រ្តូស ១០% = យកជិចស្រ្តូស ៥០% ចំនួន ៥០ ម.ល លាយជាមួយជិចស្រ្តូស ៥% ចំនួន ៥០០ ម.ល សម្រាប់ចាក់បញ្ចូលតាមសរសៃ**

- ត្រូវចាប់ផ្តើមអោយលេបថ្នាំនៅពេលណាដែលអ្នកជម្ងឺដឹងខ្លួនឡើងវិញ និងអាចលេបថ្នាំបាន ។
- ព្យាបាលដោយប្រើគីនីន quinine និងតេត្រាស៊ីគ្លីន /ដុកស៊ីស៊ីគ្លីន គួរបន្តឱ្យបានយ៉ាងតិចចំនួន ៧ថ្ងៃ។
- ប្រសិនបើអ្នកជម្ងឺទៅផ្ទះមុនពេលលេបថ្នាំអស់ ចូរពន្យល់ដល់អ្នកជម្ងឺអំពីរបៀបប្រើនិងពេលវេលានៃការលេបថ្នាំ។

- ត្រូវពន្យល់ជូនគាត់ពីភាពចាំបាច់នៃការលេបថ្នាំគ្រាប់ឱ្យអស់ដើម្បីកុំឲ្យជម្ងឺគ្រុនចាញ់លាប់ឡើងវិញ និងដើម្បីបង្ការភាពស៊ាំរបស់មេរោគ ទៅនឹងថ្នាំ។

*<u>កំណត់សម្គាល់សំខាន់អំពីគីនីនៈ</u>*

- ក្នុងមួយអំពូលចំណុះ 2ម.ល មានគីនីនឌីអ៊ីដ្រូក្លរីដ (quinine dihydrochloride) ចំនួន 600ម.ក្រ។
- ក្នុងករណីខ្សោយតម្រងនោម (អ្នកជម្ងឺបញ្ចេញទឹកនោមពណ៌ក្រមៅបានតិចតួច តែមានលំនឹងជាតិទឹកក្នុងខ្លួនល្អ)៖ ចូរបន្ថយកម្រិត ថ្នាំគីនីនចំនួន៥០% ក្រោយ ២៤ម៉ោង ពោលគឺឲ្យគីនីន ៥ម.ក្រ/គ.ក្រ បញ្ចូលតាមសេរ៉ូមក្នុងរយៈពេល ៨ម៉ោង (៣ដងក្នុងពេល២៤ម៉ោង)។
- បើអ្នកជម្ងឺមានទឹកនោមពណ៌ក្រមៅ (haemoglobinuria) **ហាមបញ្ឈប់ ឬ បន្ថយថ្នាំគីនីន**។បើសិនមានភាពស្លេកស្លាំងខ្លាំងត្រូវធ្វើការ បញ្ចូលឈាម។

## 5.2. ការតាមដានមើលជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរ

### 5.2.1. ការពិនិត្យតាមដានសញ្ញាគ្លីនិក៖

ការតាមដានគ្លីនិកនៃអ្នកជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរម្នាក់គឺពឹងផ្អែកលើការពិនិត្យសញ្ញាគ្លីនិកប្រចាំថ្ងៃដើម្បីរកមើលភាពប្រសើរផ្នែកគ្លីនិករបស់អ្នកជម្ងឺ ប្រៀបធៀបទៅនឹងថ្ងៃចូលសម្រាកពេទ្យ៖

- សីតុណ្ហភាព (បើលើសពី > 39°C ត្រូវយកកន្សែងត្រជាក់ជូតឲ្យអ្នក ជម្ងឺ ឬរុំកុមារនឹងកន្សែងសើម)
- សម្ពាធឈាម និងជីពចរ

- ចង្វាក់ដង្ហើម (បើសិនចង្វាក់ដង្ហើមកើនឡើង ត្រូវដាក់សេរ៉ូមឲ្យ យឺតៗ និងត្រូវកល់ក្បាលគ្រែឲ្យខ្ពស់ជាងមុន)
- បរិមាណទឹកដែលបានបញ្ចូលនិងបរិមាណទឹកនោមដែលបានបញ្ចេញ
- ត្រួតពិនិត្យល្បឿននៃការបញ្ចូលសេរ៉ូមនៅតាមសរសៃ
- តាមដានភាពស្លេកស្លាំងនៃអ្នកជម្ងឺ
- សំអាតខ្លួនអ្នកជម្ងឺ និងកុំឲ្យអ្នកជម្ងឺដេកលើគ្រែសើម

**ការថែទាំអ្នកជម្ងឺសន្លប់៖**

- វាយតម្លៃ និងតាមដានការសន្លប់ ដោយប្រើមាត្រដ្ឋាន Glasgow សម្រាប់មនុស្សពេញវ័យ ឬមាត្រាដ្ឋានវាស់កម្រិតសន្លប់របស់ Blantyre សម្រាប់កុមារ (ទំព័រ 65-66 )
- ថែទាំផ្លូវដង្ហើម(យកធ្មេញពាក់ចេញ)ដាក់ឲ្យអ្នកជម្ងឺដេកផ្អៀង ដោយភ្ញើយក្បាលទៅក្រោយបន្តិចនិងបូមស្លេសចេញពីមាត់ឲ្យស្អាត ។ល។
- ប្រែខ្លួនអ្នកជម្ងឺជារៀងរាល់ម៉ោង(សុំឲ្យគ្រួសាររបស់អ្នកជម្ងឺជួយប្រែ)
- កត់ត្រាបរិមាណសេរ៉ូមដែលបានបញ្ចូល និងទឹកនោមដែលបញ្ចេញ
- ស៊កបញ្ចូលទុយោសុងទឹកនោម ដោយប្រើបច្ចេកទេសស្ទេរីល
- បើការធ្វើរោគវិនិច្ឆ័យជម្ងឺគ្រុនចាញ់លើអ្នកជម្ងឺសន្លប់ម្នាក់ មិនច្បាស់លាស់ទេ ចូរពិចារណាបូមទឹកខួរឆ្អឹងខ្នង(lumbarpuncture) ទៅពិនិត្យ
- ជានិច្ចជាកាលត្រូវត្រួតពិនិត្យមើលកង្វះជាតិស្ករក្នុងឈាមនិងធ្វើការព្យាបាល

#### 5.2.2. ការតាមដានប៉ារ៉ាសិតសាស្ត្រ:

1) អ្នកជម្ងឺគ្រប់រូបដែលមានជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរត្រូវតាមដាន ពិនិត្យឈាមរាល់ថ្ងៃ រហូតដល់កញ្ចក់ឈាមអវិជ្ជមានពីរដងបន្តបន្ទាប់គ្នា
2) លទ្ធផលពិនិត្យកញ្ចក់ឈាមរាល់ថ្ងៃ រួមទាំងការរាប់មេរោគក្នុងឈាម នឹងអាចជួយយើងឲ្យដឹងថាតើអ្នកជម្ងឺមានការធូរស្រាលឬទេ
3) ចាំបាច់ ត្រូវជោះឈាមពិនិត្យមើល នៅថ្ងៃទី៧ ដើម្បីចង់ដឹងថាតើជម្ងឺគ្រុនចាញ់បានជាសះស្បើយឬនៅ
4) ប្រសិនបើកញ្ចក់ឈាមនៅថ្ងៃទី៧បង្ហាញពីវត្តមានហ្គាម៉េតូស៊ីតនោះគឺមិនមែនបញ្ជាក់ថាការព្យាបាលមិនបានជោគជ័យនោះទេហើយពុំចាំបាច់មានការព្យាបាលអ្វីពិសេសទៀតឡើយ

### 5.3. ការព្យាបាលបន្ថែម

#### 5.3.1. ការបំពេញជាតិទឹកឡើងវិញ

ត្រូវពិនិត្យមើលសញ្ញាខ្សោះជាតិទឹកក្នុងខ្លួនដូចជា៖

- ស្បែកស្ងួតមានផ្នត់
- ភ្នាសជាលិកា(មុយកឺ)ស្ងួត
- ទឹកនោមតិច
- ជីពចរដើរញាប់
- សម្ពាធឈាមចុះទាបខុសធម្មតា

***<u>ចំពោះមនុស្សពេញវ័យ៖</u>*** ចាក់បញ្ចូលសេរ៉ូមឡាក់តាតរីងហ្គ័រ (Ringer Lactate) ឬសេរ៉ូមប្រៃ 0.9% ចំណុះ1000 ម.លក្នុងរយៈពេល១ ម៉ោង

***ចំពោះកុមារ៖***

- សម្រាប់កុមារដែលខ្សោះជាតិទឹកធ្ងន់ធ្ងរ ត្រូវដាក់សេរ៉ូមប្រៃ 0.9% ឬឡាក់តាត រីងហ្គ័រ(LactateRinger)20-30 ម.ល/គ.ក្រ ក្នុងរយៈពេល 1-2 ម៉ោង។
- សម្រាប់កុមារដែលខ្សោះជាតិទឹកតិចតួច ត្រូវដាក់សេរ៉ូមប្រៃ 0.9% ឬឡាក់តាតរីងហ្គ័រ(LactateRinger)5ម.ល/គ.ក្រ/ម៉ោង ឬ ឲ្យ ទឹក អូរ៉ាលីត (ORS) បាញ់ចូលតាមស្បុងច្រមុះ ចំនួន 20 ម.ល/គ.ក្រ/ម៉ោង រហូតដល់មានជាតិទឹកឡើងវិញគ្រប់គ្រាន់។

***តាមដានមើលបរិមាណជាតិទឹកដែលបានបញ្ចូល និងបរិមាណទឹកនោមដែលបញ្ចេញ៖***

- ជាពិសេស នៅក្នុងករណីសន្លប់យូរថ្ងៃ
- វាស់បរិមាណជាតិទឹកដែលបានបញ្ចូល (តាមមាត់ ឬតាមសេរ៉ូម) និងបរិមាណទឹកនោមដែលបានបញ្ចេញ
- កត់ត្រាបរិមាណសេរ៉ូមដែលបានចាក់បញ្ចូលតាមសរសៃ
- ត្រូវគិតចំនួនដងនិងបរិមាណនៃការក្អួតផងដែរ

### 5.3.2. ការព្យាបាល និងការបង្ការភាពប្រកាច់៖

1) បន្ថយកំដៅ៖ ជូតខ្លួនឬដណ្តប់កន្សែងត្រជាក់, បក់ឲ្យអ្នកជម្ងឺ និងឲ្យថ្នាំប៉ារ៉ាសេតាម៉ុល (១៥ ម.ក្រ/គ.ក្រ ក្នុងមួយដូស)។
2) ឲ្យថ្នាំឌីដ្យាហ្សេប៉ាម (Diazepam) (VALIUM®)[4]:
   – *សម្រាប់កុមារ៖* 0.5ម.ក្រ/គ.ក្របាញ់បញ្ចូលតាមគូថ (ខ្ពស់បំផុតត្រឹម 10ម.ក្រ ក្នុងមួយដូស)ដោយប្រើសឺរាំងគ្មានម្ជុល

[4] Vidal 1999

– *សម្រាប់មនុស្សពេញវ័យ៖* 1 អំពូល 10 ម.ក្រ ចាក់តាមសរសៃ ឬ សាច់ដុំ (IV, IM) ឬតាមគូថ

3) ឲ្យឌីយ៉ាហ្សេប៉ាម(diazepam)រាល់១៥នាទីម្តងរហូតដល់ឈប់ប្រកាច់

**ហាមប្រើអាស្ពីរីន (ASPIRIN) ព្រោះវាបណ្តាលឲ្យមានគ្រោះថ្នាក់ចំពោះគ្រុនចាញ់ធ្ងន់ធ្ងរ**

### 5.3.3. ការរក្សាលំនឹងជាតិស្ករក្នុងឈាម៖

*ការវាយតម្លៃកម្រិតជាតិស្ករក្នុងឈាម៖*

1) ប្រើដិចស្ត្រូស្ទីក (dextrostix) បើមាន
2) បើមិនមានដិចស្ត្រូស្ទីកទេ ចូររកមើលសញ្ញាគ្លីនិក នៃកង្វះជាតិស្ករ ក្នុងឈាមដូចជា៖
   - អ្នកជម្ងឺគ្រុនចាញ់ទាំងអស់ ដែលមានវិប្បត្តស្មារតី (វង្វេងវង្វាន់ ឬ សន្លប់) ជាពិសេស កុមារ និងស្ត្រីមានផ្ទៃពោះ
   - អ្នកជម្ងឺដែលបានដឹងខ្លួន ហើយសន្លប់វិញម្តងទៀត
   - អ្នកជម្ងឺប្រកាច់
   - អ្នកជម្ងឺដែលសន្លប់កាន់តែជុនដាបទៅៗ ទោះបីបានទទួលការព្យាបាល ដោយថ្នាំប្រឆាំងនឹងជម្ងឺគ្រុនចាញ់ក៏ដោយ

*ការព្យាបាលកង្វះជាតិស្ករក្នុងឈាម៖*

• **មនុស្សពេញវ័យ៖**

ត្រូវចាក់សេរ៉ូមដិចស្ត្រូស (dextrose 50%) ចំនួន៥០ម.ល (1 ម.ក្រ/គ.ក្រ). ចូរចងចាំថា ដិចស្ត្រូស 50% មិនត្រូវចាក់ផ្ទាល់តាមសរសៃទេចាំបាច់ត្រូវលាយពង្រាវយ៉ាងតិចពីរដង ដើម្បីបង្ការការ ក្រិនសរសៃឈាម

បន្ទាប់មកចាក់បន្តដោយ ដិចស្រ្តូស Dextrose 10%

ចាក់ម្តងទៀត បើសិនអ្នកជម្ងឺមិនទាន់ធូរស្រាល

- **កុមារ៖**

ចាក់សេរ៉ូមដិចស្រ្តូស ៥០%(1ម.ក្រ/គ.ក្រ)តាមសរសៃ បន្ទាប់មកចាក់ដិចស្រ្តូស Dextrose 10%។ចាក់ម្តងទៀត បើសិនអ្នកជម្ងឺមិនទាន់ធូរស្រាល

**5.3.4. ការវាយតម្លៃស្ថានភាពតម្រងនោម៖**

* អ្នកជម្ងឺបញ្ចេញបរិមាណទឹកនោម គ្រប់គ្រាន់គឺ៖

- *មនុស្សពេញវ័យ៖* ធម្មតាលើសពី > 450 ម.ល/២៤ម៉ោង
- *កុមារ៖ ធម្មតាលើសពី* > 2 ម.ល/ម៉ោង

ត្រូវបញ្ឈប់ការបំពេញកង្វះជាតិទឹក នៅពេលណាដែលអ្នកជម្ងឺ មានជាតិទឹកឡើងវិញតាមសញ្ញាគ្លីនិក

* បើអ្នកជម្ងឺនោមតិចជាង 450 ម.ល/24ម៉ោង៖

- ពិនិត្យមើលស្ថានភាពជាតិទឹកក្នុងខ្លួន បំពេញជាតិទឹកឡើងវិញប្រសិនបើចាំបាច់
- បើសិនស្ថានភាពជាតិទឹកនៅធម្មតា ចូរតាមដានបរិមាណទឹកនោម ដែលបានបញ្ចេញនិងបំពេញបរិមាណទឹកឡើងវិញរួច បូកបន្ថែម ១០ ម.ល/គ.ក្រ សម្រាប់ការបាត់បង់ដែលមិនបានចាប់ភ្លឹក

* បើអ្នកជម្ងឺមិននោមសោះ ហើយឃើញមាន សញ្ញាជាតិទឹកគ្រប់គ្រាន់ត្រូវធ្វើតេស្តហ្វ៊ុយរ៉ូសេមីដ(FUROSEMIDE Test)

## ការធ្វើតេស្តហ្វ៊ុយរ៉ូសេមីដ FUROSEMIDE (LASILIX®) TEST:

**ប្រើហ្វ៊ុយរ៉ូសេមីដ តែនៅពេលណាដែលអ្នកប្រាកដថា អ្នកជម្ងឺមានជាតិទឹកឡើងវិញហើយ**

<u>កំណត់សម្គាល់៖</u> *កុមារកម្រណែនាំឲ្យប្រើហ្វ៊ុយរ៉ូសេមីដ*

**មនុស្សពេញវ័យ៖** ឲ្យហ្វ៊ុយរ៉ូសេមីដ៤០ម.ក្រចាក់តាមសរសៃឃើតៗ ក្នុងរយៈពេល ១៥នាទី

**កុមារ៖** ឲ្យហ្វ៊ុយរ៉ូសេមីដ ២ ម.ក្រ/គ.ក្រ ចាក់តាមសរសៃឃើតៗ

*<u>លទ្ធផលតេស្ត៖</u>*

- បើសិនអ្នកជម្ងឺនោមបាន៖គឺជាសញ្ញាល្អហើយអ្នកជម្ងឺអាចនឹងជាសះស្បើយបាន
- បើសិនអ្នកជម្ងឺមិននោមសោះ៖
  - ត្រូវបន្តធ្វើតេស្តឡើងវិញ ក្នុងរយៈពេល១ម៉ោងក្រោយដោយចាក់ហ្វ៊ុយរ៉ូសេមីដ ៨០ម.ក្រ(ឬ៤ម.ក្រ/គ.ក្រ សម្រាប់ កុមារ)
  - បើនៅតែមិននោមទៀត បន្ទាប់ពី១ម៉ោងក្រោយមក ចូរឲ្យហ្វ៊ុយរ៉ូសេមីដ ១២០ម.ក្រ (ឬ ៨ម.ក្រ/គ.ក្រសម្រាប់កុមារ)
- បើអ្នកជម្ងឺនៅតែមិននោមទៀត៖ត្រូវកំណត់បរិមាណទឹកដើម្បីបំពេញ
- ការបាត់បង់បូកនឹង១០ម.ល/គ.កសម្រាប់ការបាត់បង់ដែលមិនបានចាប់ភ្លឹក
- បើមានលទ្ធភាព ត្រូវបញ្ជូនអ្នកជម្ងឺ ទៅមន្ទីរពេទ្យដើម្បីធ្វើការលាងឈាម (peritoneal dialysis)

- មិនត្រូវឲ្យថ្នាំបញ្ចុះទឹកនោម មុនពេលបំពេញកង្វះជាតិទឹកឲ្យអ្នកជម្ងឺជាដាច់ខាត។

**5.3.5. ការព្យាបាលភាពស្លេកស្លាំង៖**

ភាពស្លេកស្លាំងអាចបង្កឡើងដោយ៖

- បែកគ្រាប់ឈាមក្រហម និងមានទឹកនោមពណ៌ទឹកតែចាស់
- ការហូរឈាម
- ការបង្ករោគក្នុងឈាម (bacterial sepsis)

ការព្យាបាល៖

ត្រូវបញ្ចូលឈាម បើសិនអេម៉ាតូគ្រីតតិចជាង១៥% ឬអេម៉ូក្លូប៊ីន (haemoglobin) តិចជាង ៦ក្រ/ដ.ល (6 g/dl):

1) ត្រូវចាក់បញ្ចូល ឈាមស្រស់ចំនួន ២០ម.ល/គ.ក្រ ឬគោលិកាក្រហមសុទ្ធចំនួន ១០ម.ល/គ.ក្រ (គោលិកាក្រហមសុទ្ធគឺល្អសម្រាប់កុមារ)
2) ថ្វីបើថ្នាំជាតិដែក មិនអាចជួយកែភាព ស្លេកស្លាំងណាដែល បង្កឡើងដោយសារការបែកគ្រាប់ឈាមក៏ដោយ តែ ជាធម្មតា ភាពស្លេកស្លាំងច្រើនតែបង្កឡើង ដោយមូលហេតុផ្សេងៗជាច្រើន ដូច្នេះ អ្នកជម្ងឺស្លេកស្លាំង ត្រូវផ្តល់ដំបូន្មានឲ្យហូបអាហារណា ដែលសម្បូណ៌ជាតិដែកនិងអាស៊ីតហ្វូលិក និងគួរឲ្យប្រើថ្នាំគ្រាប់ជាតិដែក នៅពេលទៅផ្ទះវិញ។

**5.3.6. ការព្យាបាលជម្ងឺផ្សេងដែលកើតឡើងក្នុងពេលជាមួយគ្នា**

បង្ការការកើតជម្ងឺស្ទូត៖

- ដាក់អ្នកជម្ងឺឲ្យដេកផ្អៀងទៅម្ខាង
- បូមសំអាតស្លេសពីក្នុងមាត់

<u>បង្ការជម្ងឺផ្លូវនោម៖</u>

- ប្រើទុយោសុងផ្លូវនោមដែលស្ទេរីលគ្មានមេរោគ
- ដុះលាងសំអាតដៃឲ្យស្អាត
- ប្រើស្រោមដៃស្ទេរីល
- ត្រូវជូតសំអាតដោយថ្នាំសំលាប់មេរោគត្រង់កន្លែងផ្លូវនោមមុនពេលដាក់បញ្ចូលសុង

<u>ការព្យាបាលជម្ងឺរួមផ្សំផ្សេងៗ៖</u>

1) ប្រសិនបើមានសញ្ញាបង្ករោគក្នុងសួតដូចជា:
   - ចង្វាក់ដង្ហើមដើរញាប់
   - ក្អក
   - ស្នូរប្រេះប្រស់តូចឆ្មារក្នុងសួត(ពេលស្តាប់សួត)

ត្រូវព្យាបាលឲ្យបានរហ័សជាមួយអង់ទីប៊ីយ៉ូទិក យោងតាមមគ្គុទ្ទេសក៍គ្លីនិក និង ព្យាបាលសម្រាប់មន្ទីរពេទ្យបង្អែករបស់ក្រសួងសុខាភិបាល

2) ប្រសិនបើមានសញ្ញាបង្ករោគក្នុងឈាម (សិបទីសេមី)ដូចជា:
   - សម្ពាធឈាមធ្លាក់ចុះ
   - ស្បែកត្រជាក់ស្អិត
   - ជីពចរដើរញាប់ និងខ្សោយ

ត្រូវព្យាបាលឲ្យបានរហ័សជាមួយអង់ទីប៊ីយ៉ូទិក យោងតាមមគ្គុទ្ទេសក៍គ្លីនិក និង ព្យាបាលសម្រាប់មន្ទីរពេទ្យបង្អែករបស់ក្រសួងសុខាភិបាល

### 5.3.7. ការព្យាបាលផលវិបាកដទៃទៀត៖

<u>*ហើមសួតស្រួចស្រាវ (APO)*</u>

ស្ថានភាពធ្ងន់ធ្ងរនេះអាចសម្គាល់ដឹងដោយ៖

- ចង្វាក់ដង្ហើមកើនឡើង
- ស្នូរប្រេះប្រស់ពេលស្តាប់សួត

ហើមសួតស្រួចស្រាវនេះអាចបង្កឡើងដោយបញ្ចូលជាតិទឹកលើសចំនួន ឬ ដោយមេរោគគ្រុនចាញ់ដែលធ្វើឲ្យខូចខាតសរសៃឈាមសួតតែម្តង។

**ការព្យាបាល៖**

1) ដាក់អ្នកជម្ងឺដេកក្នុងស្ថានភាពផ្ងើយដងខ្លួន
2) បញ្ឈប់ ឬបន្ថយល្បឿនបញ្ចូលសេរ៉ូមតាមសរសៃ
3) ដាក់អុកស៊ីសែនដែលមានកំហាប់ខ្ពស់
4) ចាក់ហ្វ៊ុយរ៉ូសេមីដ៤០ ម.ក្រ តាមសរសៃ (furosemide 40 mg IV)
5) បើសិនអ្នកជម្ងឺនៅតែមិននោម បង្កើនហ្វ៊ុយរ៉ូសេមីដជាបន្តបន្ទាប់ រហូតដល់ ១២០ម.ក្រ តាមសរសៃ។

*ការហូរឈាមដោយឯកឯង និងកំណកឈាមរាយប៉ាយក្នុងសរសៃឈាម (DIC)*

សញ្ញាគ្លីនិក៖

- ហូរឈាមតាមជើងធ្មេញ តាមច្រមុះ ស្នាមជាំក្រោមស្បែក ភ្នែកឡើងក្រហម
- ក្អួតឈាម និងជុះឈាម(លាមកពណ៌ខ្មៅ)

ការព្យាបាល៖

1) បន្តដាក់សេរ៉ូមតាមសរសៃ
2) បញ្ចូលឈាមស្រស់
3) ចាក់វីតាមីនកា(Vit.K)តាមសរសៃក្នុងល្បឿនយឺតៗចំនួន ១០ម.ក្រ សម្រាប់មនុស្សពេញវ័យ

***<u>ទឹកនោមពណ៌ទឹកតែចាស់ (Haemoglobinuria)</u>***

គំហើញគ្លីនិក៖

- អ្នកជម្ងឺដែលមានកង្វះ G6PD ដែលលេបថ្នាំព្រីម៉ាគីន
- គ្រុនមានទឹកនោមពណ៌ខ្មៅ(បណ្តាលមកពីមាន Hemoglobinuria រួមជាមួយភាពស្លេកស្លាំង និងការខូចតម្រងនោម)ដែល ជាធម្មតាកើតឡើងនៅពេលអ្នកជម្ងឺបានលេបថ្នាំគីនីន (quinine) ឬ មេហ្វ្លូគីន (mefloquine) មិនបានត្រឹមត្រូវ។

*ការព្យាបាល៖*

1) បន្តការព្យាបាលដោយថ្នាំប្រឆាំងនឹងគ្រុនចាញ់ឲ្យបានត្រឹមត្រូវ
2) បញ្ចូលឈាមស្រស់ បើចាំបាច់
3) ជួនកាលត្រូវធ្វើ Peritoneal dialysis បើចាំបាច់

# 6. វិធីព្យាបាលជម្ងឺគ្រុនចាញ់ចំពោះកុមារ

## 6.1. រោគវិនិច្ឆ័យបែបគ្លីនិក

*លក្ខណៈនៃជម្ងឺគ្រុនចាញ់ស្រាល[5]:*

- ប្រវត្តិនៃការធ្វើដំណើរទៅ ឬរស់នៅ ក្នុងតំបន់ចំលងជម្ងឺគ្រុនចាញ់
- ប្រកាច់ដោយសារគ្រុនក្តៅខ្លាំង ៣៩ ទៅ ៤០ អង្សាសេ
- មានបញ្ហាក្រពះចំពោះទារកនិងកុមារតូច ដូចជាចង់ក្អួតចង្អោរ ក្អួត និងជួនកាល រាក
- សំណុំរោគសញ្ញាត្រជាក់ស្រឹបៈ យំ និងនៅមិនស្ងៀមចំពោះទារក និងកុមារតូច, ឈឺក្បាលចំពោះកុមារធំ ជារឿយៗមានរួមផ្សំ នឹងហើមពោះស្រួចស្រាវ (ស្រដៀងគ្នានឹងពោះដែលធ្វើការវះកាត់)
- សំណុំរោគសញ្ញាសរសៃប្រសាទៈ សន្លឹម, វង្វេងវង្វាន់, ឈឺដូចរលាកស្រោមខួរ, ធ្វើឲ្យនឹកឃើញដូចជម្ងឺរលាកខួរក្បាល
- ការធ្លាក់អណ្តើកច្រើនកើតឡើងជាញឹកញាប់ និងអាចរួមផ្សំ ជាមួយថ្លើមរីកធំ
- រោគសញ្ញាទងសួត-បំពង់ខ្យល់ៈ ច្រើនមានក្អក ជួនកាលមានពងបែកក្នុងមាត់ (ដែលអាចធ្វើឲ្យច្រឡំ)

[5] Martin Danis et Jean Mouchet. Paludisme. Universités Francophones, Ellipses/Aupelf, 1991

***កំណត់សម្គាល់៖***

មានការពិបាកក្នុងការវែកញែក ឲ្យឃើញភាពខុសគ្នានៃជម្ងឺគ្រុនចាញ់ស្រាល ពីជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរចំពោះកុមារ ដែលមានរោគសញ្ញាផ្នែកសរសៃប្រសាទ។ តាមពិត គ្រុនក្តៅខ្លាំងអាចបង្កឲ្យទៅជារវើរវាយមួយរយៈពេលខ្លី ដែលបាត់ទៅវិញនៅពេលកំដៅចុះមកធម្មតាវិញ។គ្រុនក្តៅខ្លាំងពេកក៏អាចបណ្តាលឲ្យកុមារអាយុ៤ ទៅ៥ ឆ្នាំប្រកាច់បានដែរប៉ុន្តែការប្រកាច់នេះជាទូទៅកើតឡើងតែមួយដងគត់។

**ដោយហេតុថាស្ថានភាពគ្លីនិករបស់កុមារមានសភាពដុនដាបរហ័ស** (ជួនកាល ២-៣ថ្ងៃបន្ទាប់ពីគ្រុនក្តៅចាប់ផ្តើម)ដូច្នោះ ការព្យាបាលសម្រាប់ជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរឬមានផលវិបាកត្រូវធ្វើឲ្យបានឆាប់បំផុតដែលអាចធ្វើទៅបាន **សម្រាប់សញ្ញាជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរឬមានផលវិបាក(សូមមើលទំព័រទី14)**

## 6.2. ការព្យាបាលជម្ងឺគ្រុនចាញ់ស្រាលចំពោះកុមារ

### 6.2.1. ការព្យាបាលដោយផ្អែកលើលទ្ធផលតេស្តវិនិច្ឆ័យរហ័ស ឬកញ្ចក់ឈាមស្តើង-ក្រាស់ ផ្លា.ហ្វាល់ស៊ីប៉ារ៉ូម ផ្លា.វីវ៉ាក់ ផ្លា.ម៉ាឡារីយេ ឬ គ្រុនចាញ់ឆ្លងចំរុះ៖

ការព្យាបាលជម្រើសទី១ សម្រាប់ជម្ងឺគ្រុនចាញ់ស្រាលប្រភេទ *ផ្លា.ហ្វាល់ ស៊ី ប៉ារ៉ូម ផ្លា. វីវ៉ាក់ ផ្លា.ម៉ាឡារីយេ* ឬចម្រុះ ចំពោះកុមារ គឺ៖

- ឌីអ៊ីដ្រូអាតេមីស៊ីនីន+ពីពេរ៉ាគីន(dihydroartemisinin+piperaquine)៖ 2-4 ម.ក្រ/គ.ក្រ DHA និង 20 ម.ក្រ/គ.ក្រ piperaquine
- ព្រីម៉ាគីន0.75ម.ក្រ/គ.ក្រមួយដូសគត់សម្រាប់ផ្លា.ហ្វាល់ស៊ីប៉ារ៉ូម
- ព្រីម៉ាគីន0.75ម.ក្រ/គ.ក្រ ក្នុងមួយសប្តាហ៍ x 8 សប្តាហ៍សម្រាប់ផ្លា.វីវ៉ាក់

ថ្នាំព្រីម៉ាគីន ត្រូវបានណែនាំ ឲ្យប្រើប្រាស់ ដោយអង្គការសុខភាពពិភពលោក នៅតាមកន្លែងផ្តល់សេវាសុខភាពខ្លះគួរធ្វើការតេស្តរកមើល ភាពចុះខ្សោយនៃសារធាតុ **G6PD** នៅក្នុងឈាមស៊ិន មុននឹងព្យាបាលថ្នាំ ព្រីមីគីន ឱសថព្រីម៉ាគីនហាមប្រើចំពោះក្មេងអាយុក្រោម 1 ឆ្នាំ

***ចំណាំ៖***

កម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់ណែនាំប្រើប្រាស់ **អាតូវ៉ាកូន-ប្រូកានីល** *Atovaquone-proguanil* ឬ **អាតេមីស៊ីនីន-ពីរ៉ូណារីឌីន** Artesunate-Pyronaridine ដោយសង្កេតមើលផ្ទាល់ *(Directly Observed Treatment)* ជាមួយ ការតាមដានយ៉ាងតឹងរឹងក្នុងពេល២៨ថ្ងៃសម្រាប់ **ផ្លា.ហ្វាល់ស៊ីប៉ារ៉ូម** ក្នុងខេត្តប៉ៃលិន និងតំបន់ដទៃទៀតនៅភាគខាងលិចប្រទេសកម្ពុជា ដែល មានភាពស៊ាំ និង *ACT* (*សូមស្នើសេចក្តីណែនាំពិសេសពី* មជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹង ជម្ងឺគ្រុនចាញ់)

***កម្រិតប្រើ៖***

**សម្រាប់កុមារពី 3ខែដល់ក្រោម 15 ឆ្នាំ** ការព្យាបាលជម្រើសទី១ មានដូចខាងក្រោម៖

| ទម្ងន់ (គ.ក) | អាយុ (ឆ្នាំ) | ថ្ងៃទី១ | ថ្ងៃទី២ | ថ្ងៃទី៣ | ចំនួនគ្រាប់សរុប |
|---|---|---|---|---|---|
| 5≤ទម្ងន់<10 | 3 ខែ≤ ទម្ងន់ <1ឆ្នាំ | 1/2គ្រាប់ | 1/2គ្រាប់ | 1/2គ្រាប់ | $1^{1/2}$គ្រាប់ |
| 10≤ទម្ងន់<19 | 1 ឆ្នាំ≤ ទម្ងន់<5ឆ្នាំ | 1គ្រាប់ | 1គ្រាប់ | 1គ្រាប់ | 3គ្រាប់ |
| 19≤ទម្ងន់<30 | 5 ឆ្នាំ≤ទម្ងន់<10ឆ្នាំ | $1^{1/2}$គ្រាប់ | $1^{1/2}$គ្រាប់ | $1^{1/2}$គ្រាប់ | $4^{1/2}$គ្រាប់ |
| 30≤ទម្ងន់<40 | 10 ឆ្នាំ≤ទម្ងន់<15ឆ្នាំ | 2 គ្រាប់ | 2 គ្រាប់ | 2 គ្រាប់ | 6គ្រាប់ |

### *6.2.2. គីនីន + ដុកស៊ីស៊ីគ្លីន (Quinine +/- doxycycline):*

ប្រើគីនីន + ដុកស៊ីស៊ីគ្លីន(Quinine +/- doxycycline) លុះត្រាតែ **ការព្យាបាលជម្រើសទី១មិនបានជោគជ័យ** ឬ បើសិនអ្នកជម្ងឺមិនអាចប្រើ ឌីអ៊ីដ្រូអាតេមីស៊ីនីន+ពីពេរ៉ាគីន បាន

***កម្រិតប្រើ៖***

1) កម្រិតថ្នាំគីនីនគឺ 10 ម.ក្រ/គ.ក្រ x 3 ដង ក្នុងរយៈពេល 24 ម៉ោង (30ម.ក្រ/គ.ក្រ/ថ្ងៃ)
2) កម្រិតថ្នាំដុកស៊ីស៊ីគ្លីន គឺ 100 ម.ក្រ/គ.ក្រ x 2 ដង ក្នុង 24 ម៉ោង សម្រាប់មនុស្សពេញវ័យ ( ចំពោះក្មេងក្រោម 8ឆ្នាំ: 2ម.ក្រ/គ.ក្រ x 2ដង ក្នុង24ម៉ោង)ឬ តេត្រាស៊ីគ្លីន 8.3ម.ក្រ/គ.ក្រ x 3 ដង ក្នុង24ម៉ោង (25ម.ក្រ/គ.ក្រ/ថ្ងៃ)
3) **ការព្យាបាលដោយ គីនីន + ដុកស៊ីស៊ីគ្លីន ត្រូវតែធ្វើឡើងរយៈពេល 7 ថ្ងៃ**

4) បើអាចធ្វើបាន ត្រូវព្យាបាលអ្នកជម្ងឺតាមទម្ងន់។ បើគ្មានជញ្ជីងថ្លឹងទេ ត្រូវព្យាបាលតាមអាយុ (មើលទំព័រ 71-72)

## 6.3. ការព្យាបាលជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរចំពោះកុមារ

### 6.3.1. អាតេស៊ូណាត តាមសរសៃ (Artesunate IV) ឬ អាតេមេទែរ តាមសាច់ដុំ (artemether IM) បូកនឹង DHA-PIP និងព្រីម៉ាគីន

*សេចក្តីណែនាំ៖*

នេះគឺជាការព្យាបាលជម្រើសទី១ សម្រាប់ជម្ងឺគ្រុនចាញ់ធ្ងន់ធ្ងរ (មើលទំព័រ 30-34)

*ការរក្សាលំនឹងជាតិទឹក៖*

- **កុមារទម្ងន់លើស ២៥គ.ក្រ៖**

  ចាក់សេរ៉ូមតាមសរសៃ: ៥០០ ម.ល × ៣ដង ក្នុង 24 ម៉ោង

  = ដិចស្រ្តូស dextrose 5% ឬដិចស្រ្តូស dextrose 10% ចំនួន 2ដប, បូកនឹងសេរ៉ូមប្រៃ 0.9% ចំនួន 1 ដប.

- **កុមារទម្ងន់ស្មើ ឬតិចជាង២៥គ.ក្រ៖**

  គណនាបរិមាណសេរ៉ូមដែលត្រូវការ ដូចខាងក្រោម៖

| ទម្ងន់ខ្លួន | បរិមាណសេរ៉ូម |
|---|---|
| <10 គ.ក្រ | 100 ម.ល/គ.ក្រ/24ម៉ោង |
| 10 - 25 គ.ក្រ | 60-90 ម.ល/គ.ក្រ/24ម៉ោង |

ប្រើដិចស្រ្តូស dextrose 10% ឬ dextrose 5% ឆ្លាស់គ្នានឹងសេរ៉ូមប្រៃ 0.9% ដើម្បីរក្សាសមាមាត្រសេរ៉ូមដិចស្រ្តូ 2 ភាគលាយនឹងសេរ៉ូមប្រៃ 1ភាគ

*សេចក្តីណែនាំ៖*

- បើពុំអាចថ្លឹងអ្នកជម្ងឺបាន ចូរប៉ាន់ស្មានទម្ងន់អ្នកជម្ងឺ
- បើសិនមួយដូសថ្នាំតិចជាងមួយដប ថ្នាំដែលនៅសល់គួរបោះចោល បើមិនបានប្រើភ្លាមៗសម្រាប់អ្នកជម្ងឺម្នាក់ទៀតទេ
- ត្រូវចងចាំថាថ្នាំដែលបានលាយទុកលើសពី ១ ម៉ោងពុំអាចប្រើ ប្រាស់បានទេ
- បរិមាណកម្រិតដូសគួរបង្គ្រប់ជាចំនួនគត់គិតជាម.ល ( ឧទា. សម្រាប់កុមារដែលត្រូវការតែ ៤.៣ ម.ល គួរឲ្យដល់ ៥ ម.ល)
- ថ្នាំចាក់តាមសរសៃត្រូវចាក់យឺតៗ ពី ៤ ទៅ ៥ នាទី
- ថ្នាំបន្ទាប់ពីលាយរួចត្រូវចាក់ភ្លាម
- បោះចោលសូលុយស្យុងណាដែលមិនបានប្រើក្នុងអំឡុងពេល 1ម៉ោង ក្រោយពេលលាយរួច
- ត្រូវរៀបចំសូលុយស្យុងថ្មី សម្រាប់ការចាក់ថ្នាំមួយលើកៗ
- បើអ្នកជម្ងឺដឹងខ្លួនឡើងវិញ ហើយអាចលេបថ្នាំគ្រាប់បាន**មុន ថ្ងៃ ទី៥** នៃការព្យាបាលដោយថ្នាំអាតេសូណាតតាមសរសៃ ឬសាច់ដុំ (IV/IM) ឬ អាតេមេទែតាមសាច់ដុំ (IM) ចាំបាច់ ត្រូវ ឲ្យ លេប ថ្នាំ DHA-PIP និងព្រីម៉ាគីន ដោយឲ្យគាត់លេបថ្នាំ ដូស ដំបូង នៅ ចំពោះមុខយើង

ឧទាហរណ៍៖ អាតេស៊ូណាត IV

| ទម្ងន់អ្នកជម្ងឺ | ម.ក្រ/គ.ក | ដូសសរុប (ម.ក្រ) | ចំនួនអំពូល *(60ម.ក្រ)* | សូដ្យូមប៊ីកាបូណាត*5%* | សេរ៉ូមប្រៃធម្មតា/ជិកត្រូស*5%* |
|---|---|---|---|---|---|
| 25 គ.ក្រ | 2.4 | 60 | 1 | 1 | 5ម.ល |
| 12.5 គ.ក្រ | 2.4 | 30 | 0.5 | 0.5 | 2.5ម.ល |

**ចំណាំ៖* 60ម.ក្រIV + 1ម.ល 5%សូដ្យូមប៊ីកាបូណាត + 5ម.ល សេរ៉ូមប្រៃធម្មតា ឬ 5% dextrose = 6ម.ល

ឧទាហរណ៍៖ អាតេស៊ូណាត IM

| ទម្ងន់អ្នកជម្ងឺ | ជា ម.ក្រ/គ.ក | ដូសសរុប (ម.ក្រ) | ចំនួនអំពូល *(60 ម.ក្រ)* | សូដ្យូមប៊ីកាបូណាត*5%* | សេរ៉ូមប្រៃធម្មតា /ដិកត្រូស*5%* |
|---|---|---|---|---|---|
| 25 គ.ក | 2.4 | 60 | 1 | 1 | 2ម.ល |
| 12.5 គ.ក | 2.4 | 30 | 0.5 | 0.5 | 1ម.ល |

**ចំណាំ៖* 60ម.ក្រIM + 1ម.ល 5%សូដ្យូមប៊ីកាបូណាត + 2ម.ល សេរ៉ូមប្រៃធម្មតា ឬ ទឹក = 3ម.ល

***ឧទាហរណ៍៖ អាតេម៉េទែរ IM*** ចំពោះកុមារអាយុ១២.៥គ.ក្រ ត្រូវឲ្យ៖

**ថ្ងៃទី1៖** ប្រសិនបើគ្មានអាតេស៊ូណាតIVត្រូវផ្តល់អាតេម៉េទែរ

3.2ម.ក្រx12.5គ.ក្រ = 40ម.ក្រ (ស្មើនឹងកន្លះអំពូល)។ ក្នុងអំពូល 1ម.ល មានអាតេម៉េទែរ 80ម.ក្រ ដូច្នេះចំពោះ អ្នកជម្ងឺនេះត្រូវឲ្យ៖

$\frac{(1x40)}{80}$ = 0.5 ម.ល (= 40ម.ក្រ)

ត្រូវប្រើសឺរ៉ាំង 1 ឬ 2 ម.ល ដើម្បីបូមថ្នាំអាតេម៉េទែរ 0.5 ម.ល

**ចាប់ពីថ្ងៃទី2 ដល់ថ្ងៃទី5៖** ឲ្យអាតេម៉េទែរ 1.6ម.ក្រ x 12.5គ.ក្រ = 20ម.ក្រ IM(=1/4អំពូល)ចាក់រហូតដល់៥ថ្ងៃ ។ ក្នុងអំពូលកំរិត1ម.លមានអាតេម៉េទែរ80ម.ក្រដូច្នេះត្រូវធ្វើការចាក់តាមសាច់ដុំក្នុងកំរិត៖

$\frac{(1x20)}{80}$ = 0.25 ម.ល (= 20ម.ក្រ)

## កំណត់សម្គាល់

## ប្រសិនបើការដឹកជញ្ជូនអ្នកជម្ងឺមានរយ

### 7.3.2. ɛ nj Ů

r̂ ǿ (ARTESUNATE) À R̀
ű Ů ɨ Ů ɨ + î
(DHA-PIP) r̂ ǿ + ű (A+M)
.

### 7.4. Ů ŋ î ɛ nj

– ɛ nj Ů ŋ
ấLj
Ů ŋ

– ɛ nj ǵ î Ů ŋ
Ů nj Ů ŋ (VMW)
Ű



## 9. ឧប



ប្រសិនបើមានរូបមន្តថ្នាំ DHA- PIP ( 20mg /160mg) ចូរព្យាបាលកុមារដូច តារាងខាងក្រោម

**ឌីអ៊ីដ្រូអាតេមីស៊ីនីន ២០ម.ក្រ**

***តារាងទី៣៖***

ដូសអាតេស៊ូណាតអំពូល 60 ម.ក្រ (តាមសរសៃ ឬតាមសាច់ដុំ) សម្រាប់កុមារ និងមនុស្សពេញវ័យ

អោយអាតេស៊ូណាត 2.4ម.ក្រ/គ.ក្រ (តាមសរសៃ ឬតាមសាច់ដុំ)យោងទៅតាមទំងន់ នៅតាមពេលដូចខាងក្រោម៖ ក្រោយ12 ម៉ោង ដូស 2, ក្រោយ 12ម៉ោងដូស 3, បន្ទាប់មកបន្តការព្យាបាលរៀងរាល់ 24 ម៉ោងរហូតដល់អតិបរមា 7 ដូស

ឧទាហរណ៍៖ អាតេស៊ូណាត តាមសរសៃ

**ទំងន**

* *ចំណាំ៖* 60ម.ក្រ IV + 1ម.ល 5%សូដ្យូមប៊ីកាបូណាត + 5ម.ល សេរ៉ូមប្រៃ ឬ 5% dextrose = 6ម.ល

| ទំងន់អ្នកជម្ងឺ (គ.ក) | អាតេស៊ូណាត (ម.ក្រ/គ.ក) | ដូសសរុប (ម.ក្រ) | ចំនួនអំពូល (60ម.ក្រ) | [illegible]% [illegible]ាបូណាត ([illegible]) |
|---|---|---|---|---|

**ណាដូស[redacted]បញ្ជូនទៅមន្ទីរពេទ្យបង្អែក[redacted]**

[redacted]តែសូណាតស៊ីបើ[redacted]ម.ក្រ/គ.ក្រ) មុនពេលបញ[redacted]

[redacted]ទៅមន្ទីរពេទ្យបង្អែកដែល[redacted]ុត

[redacted]

## មិនត្រូវឲ្យជុក

## ឧទាហរណ៍៖

**ទម្ងន់ (គ.ក)**



